ឧត្តមប្រឹជា **ចាប ពិន**

# ឱគេកាយ



ព.ស. ២៤៩៤ - គ.ស. ១៩៥២

**ចម្លងតាមច្បាប់ដើម**

ព.ស. ២៥៥៥ - គ.ស. ២០១២

ក្រុងម៉ុងរអាល - កេបិក - កាណាដា

**សម្រាប់ជាធម្មទាន**

# ឧគរកាយ

## គតិធម៌ ធៀប គតិលោក

រៀបរៀងដោយ

ឧត្តមប្រីជា **ចាប ពិន** និពន្ធបណ្ឌិត

អតីតអ្នកនិពន្ធតែងសេចក្ដី និងអធិបតីក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ
នៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត ក្រសួងធម្មការ

**ព.ស. ២៤៩៤ - គ.ស. ១៩៥២**

*ចម្លងតាមច្បាប់ដើមដោយខ្ញុំព្រះករុណា ខ្ញុំបាទ **ទ៉ាត តិរក្ស**

**ព.ស. ២៥៥៥ - គ.ស. ២០១២**

ក្រុងម៉ុងរេអាល - កេបិក - កាណាដា

## សៀវភៅចាស់ដែលបានចម្លងជាថ្មី ៖

១. ស្នាព្រះហស្តក្រោយបង្អស់នៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត**

២. ធម៌នមស្ការព្រះរតនត្រ័យ ពិស្តារ - សង្ខេប

៣. ប្រស្នា គិហិប្រតិបត្តិពិស្តារ ( ឈឹម ទូច, សុង ស៊ីវ )

៤. ប្រជុំនានាធម៌សង្វេគ ( ជ័យ ម៉ៃ )

៥. អានាបានស្សតិកម្មដ្ឋាន វិបស្សនាបញ្ហាធម្មបរិយាយ ( គង់ ឌឹប )

៦. ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ( ប៊ុត សាវង្ស, ព្រះភិក្ខុ សាន សុជា )

៧. ជីវិតកថា ( មុិញ សារ៉ាន )

៨. ធម្មប្រទីប ( ប្រជុំកងធម៌ យិន វន់ )

៩. រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )

១០. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )

១១. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុំ ស៊ុម )

១២. ត្រៃកូដធម៌ ( សុង ស៊ីវ )

១៣. ឱវាទបាតិមោក្ខ ( ចាប ពិន )

# ពាក្យប្រារព្ធ

*សៀវភៅ* “ **នគរភាយ** ” *ត្រូវបានរៀបរៀងឡើងដោយលោក* ឧត្តមប្រឹជ្ញា **ចាប ពិន** និពន្ធបណ្ឌិត *តាមលំអានសាស្ត្រាស្លឹករឹតបុរាណតាំងពីមុនសតវត្សទី ២០ មកម៉្លេះ ( ព.ស. ២៤៩៤ ត្រូវនឹងគ.ស. ១៩៥២ ) ។*

*ឧបាសក* **ម៉ុញ្ញ សាវ៉ាន** *លោកយល់ថា គឺជាស្នាដៃដ៏វិសេសមួយក្នុងវិស័យព្រះពុទ្ធសាសនា ដែលជួយអប់រំបន្ទំនិស្ស័យសត្វ ឲ្យដឹងសេចក្ដីពិតអំពីកាយនិងចិត្ត ឲ្យស្គាល់ច្បាស់នូវទោសនៃ* **ជាតិ ជរា ព្យាធិ មរណៈ** *ដែលនាំឲ្យសត្វលោកហែលវិលវល់នៅក្នុងសមុទ្រនៃវដ្ដសង្សារនេះផង លោកក៏បានពិគ្រោះនឹងខ្ញុំព្រះករុណា ខ្ញុំបាទ គឺដើម្បីធ្វើឲ្យសៀវភៅ* “ **នគរភាយ** ” *នេះនៅមានព្រលឹង មានជីវិតរស់ឡើងវិញ ( ដោយស្នាមគំនូសនៃអត្ថបទនេះត្រូវបានគេបោះពុម្ព ជាច្រើនលើកច្រើនសា កន្លងមកអស់រយៈពេលយូរមានការរលុបពិបាកដល់ការអានផង ) ជាកេរ្តិ៍ដំណែលវែងឆ្ងាយទៅក្នុងពេលអនាគតផង ខ្ញុំព្រះករុណា ខ្ញុំបាទ ក៏ព្យាយាមសរសេរចម្លងឡើងវិញឲ្យសមតាមបំណងលោក* ឧត្តមប្រឹជ្ញា **ចាប ពិន** *ផងដែលលោក*

*ចង់ឲ្យចម្លងសៀវភៅរឿង " **នគរភាយ** " នេះ ជាការតអាយុព្រះពុទ្ធសាសនា ។*

*ខ្ញុំបាទ សូមលើកហត្ថទាំងទ្វេ លំអោនកាយ វាចាចិត្តគោរពដល់លោកដែល ជាអ្នកប្រាជ្ញ ជាបណ្ឌិត ដែលជាម្ចាស់សៀវភៅ " **នគរភាយ** " នេះ សូមលោកអនុញ្ញាតដល់ខ្ញុំដើម្បីសរសេរចម្លង និងរៀបរៀងនូវសៀវភៅ " **នគរភាយ** " របស់លោកសាជាថ្មីឡើងវិញ ។*

*ក្នុងការចម្លងឡើងវិញនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ បានរៀបរៀងទំព័រជាថ្មីព្រមទាំងបានកែអក្ខរាវិរុទ្ធខ្លះផង ដោយយោងទៅតាមវចនានុក្រមខ្មែរ ( ២០០៨ ) ដែលជាស្នាព្រះហស្តរបស់សម្តេចព្រះសង្ឃរាជ* **ជួន ណាត** *ជោតញ្ញាណោ ប៉ុន្តែខ្លឹមសារនិងសំនួនវោហាររបស់អ្នកនិពន្ធនៅរក្សាទុកដូចដើម ។*

*សូមឧទ្ទិសស្នាដៃថ្មីនៃសៀវភៅរឿង " **នគរភាយ** " នេះ ថ្វាយ ប្រគេន ជូនដល់ ៖*

❖ **សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ**
**ប.អ.ស - អ.ម.វ**[១]

❖ លោកឧត្តមប្រឹជា **ចាប ពិន** និពន្ធបណ្ឌិត

*ដែលលោកបានបន្សល់ទុកនៅមរតកអក្សរសាស្ត្រសម្រាប់កូនចៅ ខ្មែរជំនាន់ក្រោយ ។ សូមព្រះអង្គ លោក ទទួលជ្រាបគោលបំណងល្អរបស់ខ្ញុំព្រះករុណា ខ្ញុំបាទ ហើយអនុមោទនា និងបានសោយសុខតាមសមគួរដល់ គតិភពកុំបីឃ្លៀងឃ្លាតឡើយ ។*

*ទន្ទឹមនេះដែរ ខ្ញុំព្រះករុណា, ខ្ញុំ សូមទានមេត្តាខន្តីអភ័យទោសរាល់កំហុសឆ្គង ដែលកើតឡើងដោយ "* **អវិជ្ជា** *" គ្រប សង្កត់ខ្ញុំ ឲ្យភ្លាំងភ្លាត់ដោយប្រការណាសូមទានព្រះករុណាម្ចាស់ ព្រមទាំងលោក-អ្នកអានទាំងឡាយមេត្តាអនុគ្រោះ ហើយជួយ ជួសជុល កែ បំពេញចែកជូនដល់ខ្ញុំព្រះករុណា ខ្ញុំបាទ ផង ដើម្បីជាកិច្ចអនុគ្រោះចំពោះព្រះពុទ្ធសាសនាតរៀងទៅ ។*

*ដោយអំណាចកុសលចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា បានផ្តល់ជា ពលានុភាព ឲ្យយើងខ្ញុំព្រះករុណា យើងខ្ញុំ ស្រុះស្រួលមូលមតិគ្នា បរិច្ចាគបច្ច័យ តាមកម្លាំងសទ្ធា សង្វាត ខិតខំរៀបចំចាត់ចែង បោះពុម្ពជាសៀវភៅថ្មីនេះឡើងវិញ ដើម្បីប្រគេន ចែកជូនជាធម្មទាន សូមអំណាចផលានិសង្ស នៃអាមិសទាន និងធម្មទាននេះ ជួយឧបត្ថម្ភដល់ពួកសត្វ*

*ទាំងឡាយ ក្នុងចតុឳិយាជលាលោកទាំងអស់ បានទទួលឥដ្ឋ-មនុញ្ញផលគ្រប់ ៗ គ្នា ព្រមទាំងមានប្រាជ្ញាថ្វាគំនិត បដិបត្តិព្រះធម៌បានសម្រេចមគ្គផល ដល់ទីបំផុតទុក្ខកុំបីខានឡើយ ។*

**សូមអនុមោទនា** !!!

*ក្រុងម៉ុងរេអាល , ថ្ងៃ ៤ ᧱ ៦ ឆ្នាំថោះត្រីស័ក ព.ស. ២៥៥៥[១]*
*ត្រូវនឹងថ្ងៃ ពុធ ទី ១៨ ខែ ឧសភា គ.ស. ២០១១*

**មុិញ សាវ៉ាន**
**វ៉ាត ភិរក្ស**



---

( ១ ) អានថា បណ្ឌិតអក្សរសាស្ត្រ - អភិធជមហារដ្ឋគុរុ ( អ:ភិធ:ជ: ម:ហារ័ត-ប:គុរុ )
(២) អានថា ថ្ងៃពុធ ១ រោច ខែពិសាខ ឆ្នាំថោះត្រីស័ក ព.ស.២៥៥៥

# សំនាំដើម

## ( លើកទី ៦ )

*រឿង* **នគរភាយ** *នេះ បានបោះពុម្ពលើកទី ១ នៅ គ.ស. ១៩៥២ , លើកទី ២ នៅ គ.ស. ១៩៥៣ , លើកទី ៣ នៅ គ.ស. ១៩៥៧ , លើកទី ៤ នៅ គ.ស. ១៩៥៨ , លើកទី ៥ នៅ គ.ស. ១៩៦២ តែមិនជួនល្មមតាមសេចក្ដីត្រូវការរបស់សាធុជននៅឡើយ ។*

*ដោយមានលោក-អ្នកត្រូវការសួររកច្រើនពេក ទើបបោះពុម្ពលើកទី ៦ នេះឡើងទៀត ដោយតម្កល់សេចក្ដីតាមច្បាប់ដើម ។*

១៤ មីនា ១៩៧២

**ចាប ពិន**

# លំនាំដើម

## ( លើកទី ១ )

*រឿង* **នគរភាយ** *នេះ ជាគតិធម៌ ធៀប គតិលោក ដោយយកចិត្តចេតសិក ជានាមធម៌ ( ធម្មាធិដ្ឋាន ) មកតែង ជារូបធម៌ ( បុគ្គលាធិដ្ឋាន ) សន្មតជាស្រុក នគរ ស្តេច មន្ត្រី អាមាត្រ យោធាទាហាន ឲ្យមានសេចក្តីទាក់ទងគ្នា ជារឿងនិទានហូរហែ គឺធ្វើធម៌ជ្រៅឲ្យរាក់ ធម៌ក្រឲ្យងាយ ។*

*រឿងនេះ ខ្ញុំរៀបរៀង តាមលំអានសាស្ត្រាស្លឹករឹត បុរាណដែលឥតមាននាមលោកអ្នកតែង មានសេចក្តីវែង ៗ ឲ្យជានិទានខ្លី ៗ ដោយសេចក្តីអនុគ្រោះដល់កុលបុត្រអ្នកសិក្សា សូម្បីជាកុមារក៏ឲ្យអានមើលស្តាប់ឆាប់ចូលចិត្ត សេចក្តីបាន ។*

*ពុទ្ធសាសនិកជនអ្នកបុណ្យអ្នកទាន គួរតែមានរឿង* **នគរភាយ** *នេះ ទុកជាអារ្យទ្រព្យរបស់ខ្លួន សម្រាប់អានមើលផ្ទាល់ខ្លួន ឬ ឲ្យគេអានឲ្យស្តាប់ ឬ ក៏និមន្តធម្មកថិកទេសនា ក្នុងថ្ងៃសីល ឬ ពេលទំនេរ ឬក៏វេលាជរាពាធ ។*

*បើបានចារចម្លងដាក់ស៊ឹករឹត សម្រាប់និមន្តធម្មកថិក ទេសនាក្នុងទីប្រជុំបុណ្យទាន ក៏រឹតតែគាប់ប្រសើរណាស់ ជាការតអាយុព្រះពុទ្ធសាសនា ញុាំងបសាទ - សង្វេគ - សុចរិត ជាហេតុនៃបុណ្យកុសលដែលអាចផ្តល់សេចក្តីសុខ ចម្រើនក្នុងលោកនេះ លោកខាងមុខ និងញុាំងបច្ច័យនៃ ព្រះនិព្វាន ឲ្យកើតមានដល់ពុទ្ធបរិស័ទក្នុងអនាគតជា អនេកតទៅ ។*

**សូមសិរីសួស្តីកើតមានដល់លោក-អ្នកអាន**

**និង អ្នកស្តាប់ទាំងឡាយ !**

*ថ្ងៃទី ១ មករា ព.ស. ២៥៩៥ - គ.ស. ១៩៥២*

**ចាប ពិន**

## រូបនេះ ជាប្រស្នាឲ្យគិត ពិចារណាអំពីសង្ខារប្រែប្រួល



**អនិច្ចា** : សង្ខារ មិនទៀងគ្រប់មុខ; **ទុក្ខា** : មានទុក្ខច្រើនពន់ប្រមាណ;

**អនត្តា** : សូន្យសោះ មិនមែនប្រាណ; **និព្វាន** : ទើបបានបរមសុខ ។

# នគរកាយ

## គតិធម៌ ធៀប គតិលោក

### នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យ, ហើយសូមសំដែងនូវ ធម្មកថា ជាគតិធម៌ ធៀប គតិលោក ដូចតទៅនេះ ៖

**ឯកោ រាជា ចិត្តំ នាម នគរកាយេ រជ្ជំ ការេសិ ។ តស្ស អគ្គមហេសី អវិជ្ជា ទេវី នាម , បិតា មោហោ នាម , មាតា លោភទេវី នាម ។**

*សាធុសប្បុរសទាំងឡាយ !*

*ក្នុងនិរន្តរកាល, មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទ* **ចិត្តរាជ** *ជាបរមក្សត្រគ្រងរាជសម្បត្តិ ក្នុងព្រះនគរមួយឈ្មោះ* **នគរកាយ** *។ ព្រះរាជាអង្គនោះ មានព្រះអគ្គមហេសី ទ្រង់ព្រះនាមព្រះនាង* **អវិជ្ជាទេវី** *ជាទីគាប់ព្រះទ័យ ជាងព្រះស្នំទាំងពួង, ព្រះបិតា ទ្រង់ព្រះនាមព្រះបាទ* **មោហរាជ**, *ព្រះមាតា ទ្រង់ព្រះនាម* **លោភទេវី** ។

**នគរកាយ** *នោះ មានទ្វារ ៩ គឺ ៖*

- **ចក្ខុទ្វារ** ( *ទ្វារភ្នែក* ) ២ ;
- **សោតទ្វារ** ( *ទ្វារត្រចៀក* ) ២ ;
- **ឃានទ្វារ** ( *ទ្វារច្រមុះ* ) ២ ;
- **ជិវ្ហាទ្វារ** ( *ទ្វារមាត់* ) ១ ;
- **បស្សាវទ្វារ** ( *ទ្វារតូច* ) ១ ;
- **ឧច្ចារទ្វារ** ( *ទ្វារធំ* ) ១ ។

*មានប្រាង្គប្រាសាទ ៥ គឺ ៖*

១. **ចក្ខុប្រាសាទ** [១] *ជាព្រះទីនាំងសម្រាប់ព្រះមហាក្សត្រទ្រង់ទតល្បែង របាំទាំងពួង ;*

២. **សោតប្រាសាទ** *ជាព្រះទីនាំងសម្រាប់ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ សូរស័ព្ទតូរ្យតន្ត្រីទាំងពួង ;*

៣. **ឃានប្រាសាទ** *ជាព្រះទីនាំងសម្រាប់ព្រះមហាក្សត្រទ្រង់ព្រះសុគន្ធរស ;*

( ១ ). ត្រង់បទនេះ ក្នុងអភិធម្មត្ថសង្គហៈ ថា " ចក្ខុបសាទ " ។ បានជាក្នុងទីនេះថា ចក្ខុប្រាសាទ ព្រោះជាគតិធម៌ ធៀប គតិលោក ។

៤. **ជីវ្ហាប្រាសាទ** *ជាព្រះទីនាំងសម្រាប់ព្រះមហាក្សត្រទ្រង់សោយព្រះសុទ្ធាភោជនាហារដ៏មានឱជារស ;*

៥. **កាយប្រាសាទ** *ជាព្រះទីនាំងសម្រាប់ព្រះមហាក្សត្រទ្រង់គ្រឿងអលង្ការទាំងពួង មានគ្រឿងបញ្ចកកុដកណ្ឋ ជាគ្រឿងសម្រាប់រាជ្យជាដើម ។*

*ព្រះបាទ* **ចិត្តរាជ** *ព្រះអង្គមានមហាតលិក ៧ នាក់ ដែលទ្រង់តាំងទុកក្នុងឋានន្តរសក្តិទីហ្មឺន មានមុខងារផ្សេង ៗ គ្នា សម្រាប់ជារាជបម្រើតាមពេលដែលទ្រង់ត្រូវការ គឺ ៖*

១. **ហ្មឺនផស្សោ**[១] *ជាអ្នកចាប់កាន់ព្រះអង្គ ;*

២. **ហ្មឺនសញ្ញា** *ជាអ្នកសំគាល់កិច្ចការទាំងពួង, ព្រះរាជាតែងទ្រង់ប្រើឲ្យកត់សំគាល់ ;*

៣. **ហ្មឺនវេទនា** *ជាអ្នកណែនាំព្រះមហាក្សត្រឲ្យសោយអារម្មណ៍ផ្សេង ៗ មានសុខជាដើម ;*

៤. **ហ្មឺនចេតនា** *ជាអ្នកចាំទទួលព្រះរាជឱង្ការក្នុងកាលដែលព្រះរាជាត្រូវការប្រើទៅកាន់ទីណា ក៏ទៅបាន*

---

(១) ចេតសិកទាំង ៧ នេះ ក្នុងអភិធម្មត្ថសង្គហៈ ហៅថាសព្វសាធារណចេតសិក ។

ដោយរហ័ស ;

៥. **ហ្វ៊ីនឯកគ្គតា** ជាអ្នកស្លូតត្រង់ , ព្រះរាជាទ្រង់ទុកព្រះទ័យជឿយកពាក្យ ;

៦. **ហ្វ៊ីនមនសិករោ** ជាអ្នកយកចិត្តទុកដាក់នូវកិច្ចការផ្សេង ៗ ដែលព្រះរាជាទ្រង់ប្រើ ;

៧. **ហ្វ៊ីនជីវិតិន្ទ្រិយ** ជាអ្នកជួយផ្គត់ផ្គង់ព្រះជន្មព្រះរាជាឲ្យមានព្រះជីវភាព ។

ព្រះបាទ **ចិត្តរាជ** ព្រះអង្គមានបុរោហិត ៣ រូប ទ្រង់តាំងទុកក្នុងឋានន្តរសក្តិជារាជគ្រូ សម្រាប់ណែនាំព្រះអង្គក្នុងព្រះរាជពិធីផ្សេង ៗ តាមដែលទ្រង់ត្រូវការ គឺ៖

១. **រាជគ្រូវិតក្កោ**[១] ជាអ្នកណែនាំព្រះរាជាឲ្យត្រិះរិះនូវកិច្ចការផ្សេង ៗ ;

២. **រាជគ្រូវិចារោ** ជាអ្នកណែនាំព្រះរាជាឲ្យពិចារណានូវកិច្ចការផ្សេង ៗ ;

៣. **រាជគ្រូអធិមោក្ខោ**[១] ជាអ្នកណែនាំព្រះរាជាឲ្យ

(១) ចេតសិកពួកនេះ ក្នុងអភិធម្មត្ថសង្គហៈ ហៅថាបកិណ្ណកចេតសិក ។

*មានព្រះទ័យតាំងស៊ប់ក្នុងកិច្ចការផ្សេង ៗ ។*

*ព្រះបាទ* **ចិត្តរាជ** *ព្រះអង្គមានព្រះឥសី ៣ រូបដ៏ប្រកបដោយ* **អភិញ្ញា** *និង* **សមាបត្តិ** *ព្រះអង្គទ្រង់តាំងទុកក្នុងឋានន្តរសក្តិជាអ្នកពន្យល់ព្រះអង្គ គឺ៖*

១. **ព្រះបីតិ** [១] *ជាអ្នកពន្យល់ព្រះរាជាឲ្យមានព្រះអំណរដ៏ត្រជាក់ជ្រួតជ្រាបផ្សព្វផ្សាយក្នុងអារម្មណ៍ផ្សេង ៗ ;*

២. **ព្រះឆន្ទោ** *ជាអ្នកពន្យល់ព្រះរាជាឲ្យមានព្រះទ័យស្រឡាញ់នូវកិច្ចការទាំងពួង ;*

៣. **ព្រះវិរិយោ** *ជាអ្នកពន្យល់ព្រះរាជាឲ្យមានព្រះទ័យព្យាយាមក្នុងកិច្ចការផ្សេង ៗ ។*

*មិនតែប៉ុណ្ណោះ ព្រះបាទ* **ចិត្តរាជ** *ព្រះអង្គមានព្រះភិក្ខុ ៣ រូប ទ្រង់តាំងទុកក្នុងសមណសក្តិជាព្រះជីតុនសម្រាប់ជួយរំលឹកព្រះអង្គ គឺ៖*

១. **ព្រះអនិច្ចំ** *ជាអ្នករំឭកព្រះរាជា ឲ្យនឹកឃើញសេចក្តីមិនទៀងរបស់សង្ខារ ;*

---

(១) ចេតសិកពួកនេះ ក្នុងអភិធម្មត្ថសង្គហៈ ហៅថាបកិណ្ណកចេតសិក ។

២. **ព្រះទុក្ខំ** *ជាអ្នករំឭកព្រះរាជា ឲ្យទឹកឃើញសេចក្ដីទុក្ខរបស់សង្ខារ ;*

៣. **ព្រះអនត្តា** *ជាអ្នករំឭកព្រះរាជា ឲ្យទឹកឃើញសេចក្ដីមិនមានខ្លឹមសាររបស់សង្ខារ ។*

*ព្រះជីតុនទាំង ៣ រូបនេះ តែងរំឭកធម៌អាថ៌ចំពោះព្រះមហាក្សត្រ ឲ្យទ្រង់ពិចារណាឃើញតាមពិតក្នុងព្រះត្រៃ - លក្ខណញ្ញាណ មិនឲ្យព្រះអង្គធ្វេសប្រហែសក្នុងកុសលធម៌ទាំងពួង ។*

*ព្រះបាទ* **ចិត្តរាជ** *ព្រះអង្គមានព្រះញាតិវង្ស ១៤ អង្គ ជាព្រះញាតិខាងព្រះមាតា - បិតា ជា* **បាបជន** *មានយោបល់មិនប្រពៃ ព្រះអង្គតាំងទុកក្នុងឋានន្តរសក្តិទីឃុនគ្រប់រូប គឺ ៖*

១. **ឃុនមោហោ** (១) *ជាអ្នកនាំព្រះរាជាឲ្យវង្វេង ;*

២. **ឃុនអហិរិកំ** *ជាអ្នកនាំព្រះរាជាមិនឲ្យខ្មាសបាប;*

៣. **ឃុនអនោត្តប្បំ** *ជាអ្នកនាំព្រះរាជាមិនឲ្យខ្លាចបាប ;*

---

(១) ចេតសិកទាំង ១៤ នេះក្នុងអភិធម្មត្ថសង្គហៈហៅថា អកុសលចេតសិក ។

៤. **យុនឧទ្ធច្ច** ជាអ្នកនាំព្រះរាជាឲ្យរាយមាយ ;

៥. **យុនលោភោ** ជាអ្នកនាំព្រះរាជាឲ្យលោភ ;

៦. **យុនទិដ្ឋិ** ជាអ្នកនាំព្រះរាជាឲ្យយល់ខុស ;

៧. **យុនមានោ** ជាអ្នកនាំព្រះរាជាឲ្យប្រកាន់ព្រះអង្គ ;

៨. **យុនទោសោ** ជាអ្នកនាំព្រះរាជាឲ្យប្រទូស្តគេ ;

៩. **យុនឥស្សា** ជាអ្នកនាំព្រះរាជាឲ្យប្រណែនគេ ;

១០. **យុនមច្ឆរិយំ** ជាអ្នកនាំព្រះរាជាឲ្យកំណាញ់ ;

១១. **យុនកុក្កុច្ចំ** ជាអ្នកនាំព្រះរាជាឲ្យអន្ទះអន្ទែង ;

១២. **យុនថីនំ** ជាអ្នកនាំព្រះរាជាឲ្យរួញរា ;

១៣. **យុនមិទ្ធំ** ជាអ្នកនាំព្រះរាជាឲ្យងុយដេក ;

១៤. **យុនវិចិកិច្ឆា** ជាអ្នកនាំព្រះរាជាឲ្យសង្ស័យ ។

ព្រះញាតិវង្សទាំង ១៤ អង្គនេះ ជាអ្នកទុកព្រះទ័យព្រះបាទ **ចិត្តរាជ** យ៉ាងជិតស្និទ្ធ ព្រះអង្គតែងទ្រង់ប្រោសប្រាណឲ្យចូលជិតគាល់បម្រើជានិច្ចកាល ពុំដែលខានពេលណាមួយឡើយ ។

ព្រះរាជា **ចិត្តរាជ** ព្រះអង្គមានអគ្គសេនា ១៩ នាក់ជា

វរជនមានយោបល់ល្អ ព្រះអង្គតាំងទុកក្នុងឋានន្តរសក្តិទីឧកញ៉ាគ្រប់រូប គឺ ៖

១. **ឧកញ៉ាសទ្ធា**[១] ជាអ្នកនាំព្រះរាជាឲ្យជឿកម្មផល ;

២. **ឧកញ៉ាសតិ** ជាអ្នកនាំព្រះរាជាឲ្យមានព្រះស្មារតី ;

៣. **ឧកញ៉ាហិរិ** ជាអ្នកនាំព្រះរាជាឲ្យខ្មាសបាប ;

៤. **ឧកញ៉ាឱត្តប្បំ** ជាអ្នកនាំព្រះរាជាឲ្យខ្លាចបាប ;

៥. **ឧកញ៉ាអលោភោ** ជាអ្នកនាំព្រះរាជាមិនឲ្យលោភ ;

៦. **ឧកញ៉ាអទោសោ** ជាអ្នកនាំព្រះរាជាមិនឲ្យប្រទូស្តគេ ;

៧. **ឧកញ៉ាតត្រមជ្ឈត្តតា** ជាអ្នកនាំព្រះរាជាឲ្យមានព្រះទ័យជាកណ្តាល ;

៨. **ឧកញ៉ាកាយបស្សទ្ធិ** ជាអ្នកនាំព្រះរាជាឲ្យមានព្រះនាមកាយរម្ងាប់ ;

---

(១) ចេតសិកទាំង ១៩ នេះក្នុងអភិធម្មត្ថសង្គហៈ ហៅថាសោភណសាធារណចេតសិក ។

៩. **ឧកញ៉ាចិត្តបស្សទ្ធិ** ជាអ្នកនាំព្រះរាជាឲ្យមានព្រះទ័យរម្ងាប់ ;

១០. **ឧកញ៉ាកាយលហុតោ** ជាអ្នកនាំព្រះរាជាឲ្យមានព្រះនាមកាយស្រាល ;

១១. **ឧកញ៉ាចិត្តលហុតា** ជាអ្នកនាំព្រះរាជាឲ្យមានព្រះទ័យស្រាល ;

១២. **ឧកញ៉ាកាយមុទិតា** ជាអ្នកនាំព្រះរាជាឲ្យមានព្រះនាមកាយទន់ភ្លន់ ;

១៣. **ឧកញ៉ាចិត្តមុទិតា** ជាអ្នកនាំព្រះរាជាឲ្យមានព្រះទ័យទន់ភ្លន់ ;

១៤. **ឧកញ៉ាកាយកម្មញ្ញតា** ជាអ្នកនាំព្រះរាជាឲ្យមានព្រះនាមកាយគួរដល់ការងារ ;

១៥. **ឧកញ៉ាចិត្តកម្មញ្ញតា** ជាអ្នកនាំព្រះរាជាឲ្យមានព្រះទ័យគួរដល់ការងារ ;

១៦. **ឧកញ៉ាកាយបាគុញ្ញតា** ជាអ្នកនាំព្រះរាជាឲ្យមានព្រះនាមកាយជំនាញ ;

១៧. **ឧកញ៉ាចិត្តបាគុញ្ញតា** ជាអ្នកនាំព្រះរាជាឲ្យមានព្រះទ័យជំនាញ ;

១៨. **ឧកញ៉ាភាយុជុកតា** ជាអ្នកនាំព្រះរាជាឲ្យមានព្រះនាមកាយត្រង់ ;

១៩. **ឧកញ៉ាចិត្តជុកតា** ជាអ្នកនាំព្រះរាជាឲ្យមានព្រះទ័យត្រង់ ។

អគ្គសេនាទាំង ១៩ នាក់នេះ ជាទីទុកព្រះទ័យព្រះរាជា **ចិត្តរាជ** ព្រះអង្គទ្រង់តាំងទុកជាឧត្តមក្រុមប្រឹក្សាសម្រាប់ជំនុំការរាជការ ផែនទឹកផែនដីនៃ **នគរភាយ** តាំងព្រះនេត្រព្រះកាណ៌ព្រះអង្គ ។

ព្រះរាជា **ចិត្តរាជ** ព្រះអង្គគ្រប់គ្រងរាជសម្បត្តិ ជាសម្បូណ៌ាផ្ទាសិទ្ធិរាជ មានព្រះរាជអំណាចដ៏សម្បូណ៌មហិមាជាសុខសប្បាយក្នុងកាយប្រទេស ល្បីឮសុសសាយទូទៅដល់ប្រទេសនានា ។



# ឯកោ រាជា មច្ឆុ នាម មហិទ្ធិកោ អហោសិ

## សាធុសប្បុរសទាំងឡាយ !

*ក្នុងទីមិនឆ្ងាយពី* **នគរភាយ** *នោះ មានព្រះរាជាមួយព្រះអង្គទៀតព្រះនាមព្រះបាទ* **មច្ឆុរាជ** *ជាព្រះរាជាដ៏មានមហិទ្ធិឫទ្ធិ មានសន្តានអាក្រក់ តែងត្រាច់ទៅគ្របសង្កត់សព្វសត្វក្នុងត្រៃភព តាំងពីមនុស្សលោកដល់ព្រហ្មលោកឲ្យឋិតនៅក្នុងកណ្ដាប់ព្រះហស្តនៃព្រះអង្គ , ស្ដេចមានចតុរង្គសេនា ៤ កងពលធំ សុទ្ធតែជាមេទ័ពដ៏មានប្រតិពលក្នុងកលោបាយនិងយុទ្ធពិធីគ្រប់ចំពូក មានឥទ្ធិឫទ្ធិបេស្កាមហិមាអាចផ្ចាញ់បច្ចាមិត្រគ្រប់ទិសានុទិសឲ្យបរាជ័យ ឥតបីមាននរណាមួយក្នុងត្រៃលោកតស៊ូបានឡើយ ។*

*ចតុរង្គសេនា ៤ កងពលធំនោះ មានមេទ័ព ៤ នាក់គឺ ៖*

១. **នាយជាតិ** *ជាមេទ័ពមានសមត្ថភាពខាងស្ថាបនាវត្ថុធាតុផ្សេង ៗ ដែលមិនទាន់កើត ឲ្យកើតឡើង ;*

២. **នាយជរា** *ជាមេទ័ពមានសមត្ថភាពខាងធ្វើវត្ថុធាតុផ្សេង ៗ ដែលខ្លាំងបង្កើតឡើងហើយ ឲ្យទ្រុឌទ្រោមទៅ ;*

៣. **នាយព្យាធិ** ជាមេទ័ពមានសមត្ថភាពខាងធ្វើខ្មាំងដែលមានកម្លាំងរឹងប៉ឹង ឲ្យទុព្វលភាព ;

៤. **នាយមរណៈ** ជាមេទ័ពមានសមត្ថភាពខាងសម្លាប់ខ្មាំង គ្មានគេចរួចម្នាក់ ។

មេទ័ពម្នាក់ ៗ មានបរិវារច្រើន តែងចេញចូលគាល់បម្រើរក្សាការពារអង្គព្រះបាទ **មច្ចុរាជ** ជានិច្ចជាកាល, ព្រះបាទ **មច្ចុរាជ** តែងទ្រង់ប្រើទៅយាយីសម្លាប់ពួកខ្មាំងទាំងពួងក្នុងត្រៃលោក ។

កិត្តិស័ព្ទព្រះបាទ **ចិត្តរាជ** បានល្បីរន្ទឺព្សាយដល់ព្រះបាទ **មច្ចុរាជ** នោះថា មានព្រះនគរ ១ ឈ្មោះ **នគរភោយ** ជាស្រុកនិទុក្ខសុខសប្បាយក្រៃពេក, ព្រះរាជា ជាអគ្គប្រមុខ **នគរភោយ** នោះព្រះនាម ព្រះបាទ **ចិត្តរាជ** ជាបរមក្សត្រគ្រងសិរីសម្បត្តិសម្បូណ៌ដោយព្រះរាជអំណាចមហិមា ។

កាលដំណឹងនោះ ព្សាយទៅដល់ព្រះស្រោតានៃព្រះបាទ **មច្ចុរាជ** ៗ ក៏ទ្រង់វិតក្កយ៉ាងក្រៃលែង ខ្លាចក្រែងព្រះបាទ **ចិត្តរាជ** កន្ទង់វិស័យនៃព្រះអង្គ ទ្រង់មានព្រះរាជបំណងនឹងប្រើមេទ័ពទាំង ៤ កង ឲ្យទៅវាយដណ្ដើមយក

**នគរភាយ** *នោះ ឲ្យនៅក្រោមអំណាចព្រះអង្គមួយរំពេច, តែស្តេចទ្រង់ព្រះតម្រិះឃើញថា ៖*

*"ព្រះបាទ* **ចិត្តរាជ** *ជាមហាក្សត្រដ៏មានអានុភាពមហិមា មានសេនា ទាហាន នាហ្មឺន សព្វមុខមន្ត្រីកុះករបរិបូណ៌ក្រៃពេក , បើអាត្មាអញលើកកងទ័ពទៅកាច់យកភ្លាម ៗ ឃើញថាពុំងាយបានឡើយ , ណ្ហើយកុំដូច្នោះ ចាំអាត្មាអញប្រើចារទាហានទៅលលួងយកដោយកលោបាយវិញ គឺអាត្មាអញត្រូវបញ្ជូនមេទ័ពដ៏មានសមត្ថភាព ឲ្យទៅក្លែងធ្វើជាខ្ញុំបម្រើផ្ទាល់ព្រះបាទ* **ចិត្តរាជ** *ជាមុនសិន កាលបើចារទាហានអាត្មាអញទៅប្រតិបត្តិការបានសម្រេចហើយ សឹមអាត្មាអញឲ្យលើកកងទ័ពទៅវាយយកជាក្រោយ , បើធ្វើដូច្នេះ ប្រហែលជាបានងាយ" ។*

*កាលព្រះបាទ* **មច្ឆុរាជ** *ទ្រង់ព្រះតម្រិះឃើញឧបាយដូច្នេះ ក៏ទ្រង់ព្រះបញ្ជាឲ្យហៅមេទ័ពទី ១ ឈ្មោះ* **នាយជាតិ** *ចូលមកភ្លាម ។*

*លុះនាយជាតិចូលមកគាល់, ស្តេចទ្រង់ត្រាស់ថា ៖*

*" នែ* **នាយជាតិ** *! ចូរបាទទួលយកអាសាយើងក្នុងគ្រា*

ឥឡូវនេះ, ចូរបាឯងទៅកាន់ **នគរភោយ** ជាប្រញាប់, កាលទៅដល់ ចូរបាឯងទៅអែបអបធ្វើខ្លួនឲ្យជាទីជឿជិតស្និទ្ធស្នាលជាមួយនឹងសេវកាមាត្រ ព្រមទាំងមាតាបិតាវង្សាគ-ណាញាតិនៃព្រះបាទ **ចិត្តរាជ** , បើបាឯងបានជាទីស្និទ្ធស្នាលនឹងគេហើយ ចូរបាឯងចូលថ្វាយខ្លួនជាខ្ញុំ គាល់បម្រើគេជានិច្ច និងខំធ្វើរាជការគេឲ្យល្អ ឲ្យគេទុកចិត្តរាប់អានស្រឡាញ់បា ដើម្បីនឹងបានជាសេយ្យសឹកក្នុងស្រុកគេ, កាលធ្វើការបានសម្រេចហើយ ចូរបាឯងផ្ញើដំណឹងមកយើង" ។

លុះត្រាស់ដូច្នោះ ក៏ទ្រង់បញ្ជូន **នាយជាតិ** ឲ្យទៅកាន់ **នគរភោយ** ឯ **នាយជាតិ** កាលបានទទួលព្រះរាជឱង្ការហើយ ក៏នាំបរិវារធ្វើដំណើរឆ្ពោះទៅកាន់ **នគរភោយ** នោះតាមព្រះរាជបញ្ជា ។

លុះ **នាយជាតិ** បានទៅដល់កាលណា ក៏ចូលទៅធ្វើជាមិត្តស្និទ្ធស្នាល ជាមួយនឹងនាហ្មឺនសព្វមុខមន្ត្រី ដោយសេចក្ដីឆ្លៀវឆ្លាសរបស់ខ្លួន ហើយក៏ចូលទៅផ្គាប់ផ្គុនព្រះមាតា - បិតា អគ្គមហេសីនិងព្រះញាតិវង្ស នៃព្រះបាទ **ចិត្តរាជ** , កាលឃើញថា វរជនទាំងនោះ គេស្រឡាញ់

ពេញចិត្តអាណិតអាសូរខ្លួនហើយ ក៏ឲ្យគេនាំខ្លួនទៅថ្វាយព្រះមហាក្សត្រ ។ វរជនទាំងនោះ ក៏នាំ **នាយជាតិ** ទៅថ្វាយខ្លួនចំពោះព្រះបាទ **ចិត្តរាជ** ។

កាលបើមានករណីយប្លែកដូច្នេះ ព្រះបាទ **ចិត្តរាជ** ទ្រង់មានព្រះរាជឱង្ការឲ្យអញ្ជើញរាជគ្រូ **ទិតភ្នោ**, **ទិចារោ**, **អធិមោភ្នោ** ជាបុរោហិតទាំង ៣ រូប មកត្រាស់ប្រឹក្សាថា ៖

" លោកទាំងពួងយល់ឃើញដូចម្ដេចរឿងនេះ, គួរយើងទទួលយកជនបរទេសនេះទុកក្នុងស្រុកយើង ឬពុំគួរ ? " ។

ឯបុរោហិតទាំង ៣ រូបនោះ ហេតុតែជាអ្នកមិនឈ្លាសក្នុងកលោបាយផ្សេង ៗ ថែមទាំងជាអ្នកឡេះឡោះផង ឃើញអ្នកណាគេផ្គាប់ផ្គុនក៏ទន់ចិត្តទៅតាមគេ មិនគិតត្រិះរិះពិចារណារកហេតុផលឲ្យល្អិតល្អជាមុនឡើយ ។

កាលព្រះរាជាត្រាស់សួរដូច្នោះ បុរោហិតក៏ក្រាបបង្គំទូលភ្លាមថា ៖

" បពិត្រមហារាជ ដ៏ទ្រង់នូវព្រះរាជសម្ភារ ! បើមានជនបរទេសគេស្ម័គ្រចូលមកថ្វាយខ្លួន ជាខ្ញុំបម្រើក្រោមល្អងធូលីព្រះបាទព្រះអង្គ ដោយទ្រង់ឥតបង់ខាតអ្វីដូច្នេះ គួរ

ទ្រង់ទទួលយកចុះ” ។

ព្រះបាទ **ចិត្តរាជ** កាលបានទ្រង់ព្រះសណ្តាប់ដូច្នេះ ក៏ទ្រង់ព្រះរាជានុម័តិឲ្យជប់លៀង **នាយជាតិ** ហើយឲ្យគេនៅជាខ្ញុំរាជការតទៅ ។

**នាយជាតិ** បានឧស្សាហ៍ធ្វើការថ្វាយព្រះបាទ **ចិត្តរាជ** ហើយទ្រង់ព្រះរាជទានគ្រឹះស្ថានឲ្យ **នាយជាតិ** ព្រមទាំងបរិវារនៅជាសុខសប្បាយ ។

ចាប់ដើមពីនោះមក **នាយជាតិ** ព្រួតដៃជាមួយនឹងមេជាងឈ្មោះ **គណ្ឋា**, ដែលជាជាងធំនៅក្នុងនគរកាយនោះស្រាប់ នាំគ្នាឧស្សាហ៍កសាង **នគរភាយ** ត្រង់ណាដែលមិនទាន់ស្រេច ឲ្យសម្រេចដោយរហ័ស, ត្រង់ណាដែលសម្រេចហើយ ឲ្យចម្រើនឡើងសព្វទិវារាត្រីញុំាងព្រះបាទ **ចិត្តរាជ** ឲ្យទុកព្រះទ័យពន់ពេក ។

កាលបានឱកាសល្អ, **នាយជាតិ** ជាមេទ័ពទី ១ ក៏បញ្ជូនចុតហ្មាយទៅថ្វាយព្រះបាទ **មច្ចុរាជ** ថា ៖

*សូមព្រះតេជៈតម្កល់លើត្បូង,*

*សូមព្រះរាជទានក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ជីវិតសូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។*

*សូមទ្រង់ព្រះមេត្តាប្រោស !*

*ករណីដែលព្រះអង្គប្រើទូលបង្គំ ឲ្យទៅជាចារបុរសធ្វើការឯនគរកាយនោះ, ឥឡូវនេះ ទូលព្រះបង្គំធ្វើតាមព្រះរាជបញ្ជាបានសម្រេចគ្រប់ប្រការហើយ, សូមទ្រង់បញ្ជូនមេទ័ពទី២ ទៅទៀត ដើម្បីប្រតិបត្តិការថ្វាយល្អងធូលីព្រះបាទឲ្យឆាប់បានសម្រេចតទៅ ។*

*ហត្ថលេខា* **នាយជាតិ**

*ព្រះបាទ* **មច្ចុរាជាធិរាជ** *កាលទ្រង់អានចុតហ្មាយនោះហើយក៏ទ្រង់ប្រើ* **នាយជរា** *ជាមេទ័ពទី ២ ឲ្យលើកទ័ពចេញទៅទៀត ដើម្បីឲ្យមេទ័ពនោះ ធ្វើ* **នគរភាយ** *ឲ្យទ្រុឌទ្រោម ហើយនឹងបញ្ជូនមេទ័ពធំ ៗ ដទៃទៀតទៅតាមក្រោយ ។*

**នាយជរា** *ទទួលព្រះរាជឱង្ការហើយ ក៏នាំបរិវារមកកាន់* **នគរភាយ** *ដោយសួស្តី, លុះដល់ហើយតម្រង់ទៅរក* **នាយជាតិ** *ជាពួករបស់ខ្លួនដែលមកនៅមុន ។* **នាយជាតិ** *ក៏ទទួល* **នាយជរា** *ទុកនៅជាមួយគ្នាក្នុង* **នគរភាយ** *នោះដោយសេរី ឥតបីឲ្យគេនាំទៅថ្វាយព្រះបាទ* **ចិត្តរាជ** *ដូចមុនឡើយ ។*

*តាំងពីនោះមក* **នាយជាតិ** *និង* **នាយជរា** *ក៏នាំបរិវាររៀងខ្លួនត្រាច់រុករានទន្ទ្រាន* **នគរភាយ** *គឺធ្វើរូបកាយយើង , គេគ្រប់គ្នាឲ្យចាស់គ្រាំគ្រា ១ ថ្ងៃបន្តិច ៗ តាមលំដាប់ ។*

*ឯព្រះ* **អនិច្ចំ** *ជាព្រះជីតុន កាលបានជ្រាបក៏ចូលទៅថ្វាយព្រះពររំឭកព្រះបាទ* **ចិត្តរាជ** *ថា ៖*

*" បពិត្រមហារាជ ដ៏ទ្រង់នូវព្រះរាជសម្ភារ !*

ឥឡូវនេះ ព្រះ **នគរភាយ** របស់ព្រះអង្គគ្រាំគ្រាហើយ មិនមាំមួនដូចមុនទេ ដោយ **មច្ចុរាជ** ឲ្យសត្រូវពីខាងក្រៅ ចូលមកបំផ្លាញ សូមព្រះអង្គគិតគូរឲ្យមែនទែន កុំបីធ្វេសប្រហែស” ។

កាលព្រះជីតុនរំឭកដូច្នោះ, ព្រះបាទ **ចិត្តរាជ** នឹងបានព្រឺខ្លាចសូម្បីតែប៉ុនចុងសក់ក៏ទេ ដោយវង្វេងតាមព្រះនាង **អវិជ្ជាទេវី** ជាព្រះអគ្គមហេសី ពុំមានឱកាសចេញទៅទតព្រះ **នគរភាយ** បានឡើយ ។

ព្រះ **អនិច្ចំ** ជាព្រះជីតុន កាលបានឃើញព្រះបាទ **ចិត្តរាជ** នៅព្រងើយដូច្នោះ ទើបចូលទៅថ្វាយព្រះពរតឿនម្តងទៀតថា ៖

“បពិត្រមហារាជ ដ៏ទ្រង់នូវព្រះការុញ្ញភាព[១] !

ហេតុដូចម្តេចបានជាព្រះអង្គគង់ស្ងៀមដូច្នេះ ? មិនសមគួរទេព្រះអង្គ ! ឥឡូវព្រះ **នគរភាយ** របស់ព្រះអង្គគ្រាំគ្រាហើយ សូមស្តេចយាងទៅទតខ្លះផង” ។

---

(១) ការុញ្ញភាព --ភាប បា. (ន.) (ការុញ្ញ + ភាវ) ភាពនៃចិត្តដែលមានករុណា, សេចក្តីអាណិតអាសូរ ។

*លុះព្រះជីតុនដាស់តឿនដល់ពីរដង, ព្រះបាទ* **ចិត្តរាជ** *ទ្រាំគង់ស្ងៀមពុំបាន ក៏ទ្រង់ស្តេចទៅទតបន្តិច ឃើញដូចពាក្យព្រះជីតុនរំឭកមែន , តែគង់នៅស្ងៀមទៅវិញ ពុំបានគិតដល់ព្រះនគរឡើយ ។ ទោសទាំងនេះមកតែពីទ្រង់វង្វេងដោយព្រះនាង* **អចិន្ថាទេវី** ។

*កាល* **នាយជាតិ** *និង* **នាយជរា** *ជាមេទ័ពទាំង ២ នាក់ឃើញអាការដូច្នោះ ក៏បញ្ជូនសារទៅថ្វាយព្រះបាទ* **មច្ឆរាជ** *ថា ៖*

សូមព្រះតេជៈតម្កល់លើត្បូង,

សូមព្រះរាជទានក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ជីវិតសូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

សូមទ្រង់ព្រះមេត្តាប្រោស !

ឥឡូវព្រះបាទ **ចិត្តរាជ** កំពុងប្រមាទ, សូមទ្រង់បញ្ជូនមេទ័ពទី ៣ ព្រមទាំងយោធាជាបរិវារទៅទៀតដើម្បីប្រតិបត្តិការឲ្យឆាប់ បានសម្រេចទាន់ព្រះរាជហឫទ័យតទៅ ។

ហត្ថលេខា **នាយជាតិ**, **នាយជរា**

*លុះព្រះបាទ* **មច្ឆុរាជ** *បានទ្រង់ជ្រាបព្រឹត្តិការណ៍នោះ ទើបទ្រង់ព្រះរាជបញ្ជាប្រើ* **នាយព្យាធិ** *ជាមេទ័ពកំណាចទី ៣ ព្រមទាំងបរិវារ ៩៦ នាក់ គឺ* **ឆន្នទុតិរោគ** *ឲ្យមកកាន់* **នគរភាយ** *។* **នាយព្យាធិ** *ព្រមទាំងបរិវារក៏នាំគ្នាទៅតាមព្រះរាជបញ្ជា , កាលទៅដល់ហើយ* **នាយព្យាធិ** *ព្រមទាំងបរិវារ ៩៦ នាក់បានញាំញីកំទេចនូវទ្វានគរ និងបន្ទាយតូចធំព្រមទាំងគ្រឿងប្រដាប់ផ្សេង ៗ ឲ្យរលំរលាយ បាក់បែកគ្រប់អន្លើ , អ្នកនគរកើតចលាចលរកចេញចូលពុំបាន ។ ទង្វើទាំងនេះ ដោយប្រាថ្នាតែចាប់យកព្រះបាទ* **ចិត្តរាជ** *មួយមុខប៉ុណ្ណោះ ។*

*ឯព្រះ* **ទុក្ខំ** *ជាព្រះជីតុន កាលបានឃើញក៏ចូលទៅថ្វាយព្រះពរព្រះបាទ* **ចិត្តរាជ** *ថា ៖*

*" បពិត្រមហារាជ ដ៏ទ្រង់នូវព្រះតេជានុភាព !*

*ព្រះអង្គពុំទាន់ជ្រាបទេឬ ? ឥឡូវព្រះ* **នគរភាយ** *នៃព្រះអង្គវិកលវិការហើយ ដោយ* **នាយជាតិ** *ជាមេទ័ពទី ១ ដែលចូលមកនៅមុនបង្អស់គេគប់គិតគំនិតជាមួយ* **នាយជរា** *ជាមេទ័ពទី ២ និង* **នាយព្យាធិ** *ជាមេទ័ពទី ៣ ព្រមទាំង* **ឆន្នទុតិរោគ** *៩៦ នាក់ជាបរិវារនាំគ្នាធ្វើឲ្យវឹកវរ, បើព្រះអង្គ*

*ធ្វើព្រងើយកន្តើយ ព្រះ* **នគរភោយ** *មុខជាអន្តរាយពុំខាន សូមទ្រង់ជ្រាប" ។*

*ព្រះបាទ* **ចិត្តរាជ** *បរមក្សត្រ កាលបានទ្រង់ព្រះសណ្តាប់ដូច្នោះក៏រសាប់រសល់ក្នុងព្រះទ័យក្រៃពេក ទ្រង់ស្តេចចេញទៅទតសព្វសព៌ាង្គព្រះ* **នគរភោយ** *, លុះឃើញច្បាស់ក៏ទ្រង់សោយទុក្ខវេទនា ទ្រង់ព្រះកន្សែងខ្សឹកខ្សួលជាខ្លាំង រកបុគ្គលណាមួយជួយយកអាសាកំចាត់* **ព្យាធិសេនា** *ជាខ្មាំងសត្រូវពុំបាន ដោយមហាជនទាំងពួងសឹងតែខ្លាចអំណាច* **ព្យាធិសេនា** *ទាំងអស់គ្នា ។*

*លុះ* **នាយជាតិ - ជរា - ព្យាធិ** *ជាមេទ័ពទាំង ៣ នាក់បានឃើញអាការដូច្នេះ ក៏បញ្ជូនសារទៅថ្វាយព្រះបាទ* **មច្ចុរាជ** *ថា ៖*

សូមព្រះតេជៈតម្កល់លើត្បូង,

សូមព្រះរាជទានក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

សូមទ្រង់ព្រះមេត្តាប្រោស !

ឥឡូវនេះព្រះបាទ **ចិត្តរាជ** ខ្សោយកម្លាំងណាស់ហើយ សូមទ្រង់បញ្ជូនមេទ័ពទី៤ ទៅទៀតជាប្រញាប់ដើម្បី ព្រួតគ្នាចាប់តួព្រះបាទ **ចិត្តរាជ** យកមកថ្វាយយ៉ាង រួសរាន់ ។

ហត្ថលេខា **នាយជាតិ**, **ជរា**, **ព្យាធិ**

កាលព្រះបាទ **មច្ចុរាជ** បានទ្រង់ជ្រាបប្រព្រឹត្តិហេតុនោះ ក៏ទ្រង់បញ្ជូនមេទ័ពទី ៤ ធំបំផុតឈ្មោះនាយ **មរណៈ** ដ៏មានអានុភាពមហិមាជាងមេទ័ពមុន ៗ អាចប្រាបប្រាមបច្ចាមិត្រគ្រប់ទិសតំបន់ឲ្យវិនាសអន្តរាយកណ្ដាលសមរភូមិ ។ សត្តនិករក្នុងត្រៃលោក សឹងកោតខ្លាចអំណាចមេទ័ពនេះណាស់ គ្រាន់តែឮឈ្មោះថា **មរណៈសេនា** មកជិតដល់ក៏សឹងតែនាំគ្នារត់ជ្រកយកតែអាយុរៀងខ្លួន, តែទោះបីអ្នកណារត់ទៅពួនក្នុងទីណា ៗ ក្ដី ក៏ពុំដែលរួចពីកណ្ដាប់ដៃនាយ **មរណៈ** នោះបានឡើយ ។

ឯមេទ័ពទី ៤ ឈ្មោះ នាយ **មរណៈ** កាលបានទទួលព្រះរាជបញ្ជាហើយ ក៏នាំបរិវារទៅកាន់ **នគរភោយ** លុះចូលទៅផ្សំគ្នានឹងមេទ័ពទាំង ៣ នាក់ដែលមកមុននោះហើយក៏រុករានទន្ទ្រានបុកបែនញាំញីបិទទ្វារទាំង ៩ នៃ **នគរភោយ** ឲ្យង៉ឹតជុំវិញ ហើយចូលទៅដេញចាប់តួអង្គព្រះបាទ **ចិត្តរាជ** បាន ព្រមទាំងនាហ្មឺនសព្វមុខមន្ត្រីនិងអាណាប្រជាជនទាំងពួងគ្មានសល់ម្នាក់ នាំចេញចាក **នគរភោយ** ។

ឯ **នគរភោយ** នោះ កាលបើពុំមានបុគ្គលណាមួយនៅ

*ហើយក៏ទ្រុឌទ្រោមទៅ ។*

**នគរភោយ** *គឺរាងកាយយើងគេទាំងពួង, ព្រះបាទ* **ចិត្តរាជ** *គឺចិត្តយើងគេទាំងពួង និមិត្តតែចិត្តពុំឋិតនៅក្នុងរាងកាយហើយ, រាងកាយក៏ពុំអាចទប់ទល់នៅបាន តែងដល់នូវសភាពជារាងកាយស្អុយរលួយជាធម្មតា ដោយប្រការដូច្នេះ ។*

**សាធុសប្បុរសទាំងឡាយ !**

*កាលមេទ័ពទាំង ៤ នាក់ ព្រមទាំងបរិវារ ចាប់ព្រះបាទ* **ចិត្តរាជ** *បានហើយក៏នាំទៅកាន់សំណាក់ព្រះបាទ* **មច្ចុរាជ** *។ ឯព្រះបាទ* **មច្ចុរាជ** *កាលឲ្យចាប់ព្រះបាទ* **ចិត្តរាជ** *បានមកហើយ នឹងយកទុកនៅជាខ្ញុំបម្រើក៏ទេ , ត្រឡប់ជាបណ្តេញទៅវិញថា " ចូរអ្នកឯងទៅតាមយថាកម្មខ្លួនចុះ ! "។*

**លំដាប់ពីនោះ** *ព្រះបាទ* **ចិត្តរាជ** *ក៏នាំបរិពារទៅរកទីលំនៅកសាង* **នគរភោយ** *ជាថ្មីដូចមុន ។*

*ឯព្រះបាទ* **មច្ចុរាជ** *ជាស្តេចកំបាប កាលបានជ្រាបថា*

*ព្រះបាទ* ***ចិត្តរាជ*** *កសាង* ***នគរភោយ*** *ជាថ្មី  ក៏ទ្រង់ប្រើមេទ័ពទាំង ៤ ឲ្យទៅតាម  បៀតបៀនចាប់តួអង្គព្រះបាទ* ***ចិត្តរាជ*** *ឲ្យព្រាត់ចាក* ***នគរភោយ*** *ថ្មីនោះទៀត , និមិត្តតែព្រះបាទ* ***ចិត្តរាជ*** *កសាង* ***នគរភោយ*** *វេលាណា  ក៏ធ្វើឲ្យអន្តរាយវេលានោះរាល់គ្រា  ពុំដែលខានម្តងណាឡើយ ។*

*ព្រះបាទ* ***ចិត្តរាជ*** *ក៏ទ្រង់សោយទុក្ខវេទនាគ្មានស្រាកស្រាន្ត ។*

*គ្រាមួយ  ជាវេលាមានជោគវាសនាល្អ ,  ព្រះបាទ* ***ចិត្តរាជ*** *ក៏ទ្រង់ព្រះតម្រិះថា ៖ " អាត្មាអញធ្វើម្តេចនឹងបានរួចពីកណ្តាប់ដៃនៃ* ***មច្ចុរាជ*** *នេះបានអេះ ? ឱហ្ន៎ ! អាត្មាអញនឹងឲ្យទៅអារាធនាព្រះភិក្ខុជាព្រះជីតុន  និងឥសីចូលមកប្រឹក្សាគ្នា  ក្រែងរកឃើញឧបាយយ៉ាងណាខ្លះ ? " ។ លុះទ្រង់ព្រះតម្រិះហើយ  ក៏ទ្រង់ព្រះបញ្ជាប្រើមហាតលិក ២ នាក់គឺ ហ្មឺន* ***ចេតនា*** *ជាមហាតលិកស្តាំ , ហ្មឺន* ***មនសិការ*** *ជាមហាតលិកឆ្វេងថា ៖*

*" នែបាទាំងឡាយ !  ចូរបាយកអាសាយើងទៅអារាធ-នាព្រះជីតុនទាំង ៣ រូប  គឺព្រះ* ***អនិច្ចំ*** *,* ***ទុក្ខំ*** *,* ***អនត្តា*** *និង*

ព្រះឥសីទាំង ៣ រូបគឺ ព្រះ **ចីតិ** , **ឆន្ទោ** , **ទីរិយោ** នូវបុរោហិតទាំង ៣ រូបគឺ ព្រះរាជគ្រូ **ទិតភ្នោ** , **ទិចារោ** , **អធិមោក្ខោ** ហើយនិងអគ្គសេនាទាំង ១៩ នាក់ មានឧកញ៉ា **សទ្ធា** ជាដើម ឲ្យមកកាន់សំណាក់យើងក្នុងខណៈនេះ" ។

មហាតលិកទាំងពីរនាក់ ក៏ម្ទីម្ទាទៅរកវរស្រមណ៍ និង វរជនទាំងនោះតាមព្រះរាជបញ្ជា ។ វរស្រមណ៍ និង វរជនទាំងនោះ ក៏នាំគ្នាទៅកាន់ព្រះរាជសំណាក់តាមសេចក្ដីអារាធនា អញ្ជើញ , លុះទៅដល់ព្រះបាទ **ចិត្តរាជ** ត្រាស់ប្រឹក្សាការផែនដី ថា ៖

" បពិត្រលោកអ្នកនិរទុក្ខ[១] ទាំងឡាយ !

ខ្ញុំសូមប្រឹក្សានឹងលោក សូមលោកជួយរកឧបាយដើម្បីឲ្យខ្ញុំរួចចាកកណ្ដាប់ដៃនៃ **មច្ចុរាជ** " ។

ព្រះជីតុន ព្រមទាំងវរជនទាំងពួងដែលបានជួបជុំក្នុងមហាសន្និបាតនោះ ថ្វាយព្រះពរឡើងព្រមគ្នាថា ៖

---

(១) និរទុក្ខ សំ.; បា. ( គុ. ) (និទ៌ុះខ; និទ្ទុក្ខ) ដែលឥតទុក្ខ, ឥតព្រួយ ។ សរសេរក្លាយជា នេរទុក្ខ ក៏មាន ។ និទ៌ុក្ខ

" បពិត្រព្រះសម្មតិទេវរាជ !

ការប្រឹក្សាគ្រានេះជាការធំដុំណាស់ , ការនេះដែលនឹងសម្រេចដាច់ខាតទៅបាន លុះតែបានសម្តេចព្រះមហាសង្ឃ-រាជទាំង ២ ព្រះអង្គ គឺព្រះ **សមាធិន្ទ្រិយ** និងព្រះ **បញ្ញិន្ទ្រិយ** មកជាទីប្រឹក្សាផង , សូមព្រះអង្គឲ្យទៅអារាធនាសម្តេចមក " ។

ព្រះបាទ **ចិត្តរាជ** បានទ្រង់ព្រះសណ្តាប់ទីប្រជុំ ក៏ទ្រង់ត្រាស់ប្រើហ្មឺន **ឯកគ្គតា** ជាមហាតលិកដ៏មានចិត្តស្លូតត្រង់ថា ៖

" នែហ្មឺន **ឯកគ្គតា** ! ចូរបាទៅអារាធនាសម្តេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គមកជាប្រញាប់ " ។

ហ្មឺន **ឯកគ្គតា** ក៏នាំព្រះរាជឱង្ការទៅថ្វៃងទូលសម្តេចព្រះមហាសង្ឃរាជទាំង ២ ថា ៖

" បពិត្រសម្តេចដ៏ទ្រង់នូវសីលធម៌បរិសុទ្ធ !

ព្រះបាទ **ចិត្តរាជ** ត្រាស់ប្រើទូលបង្គំជាខ្ញុំឲ្យមកអារាធ-នាសម្តេចទាំង ២ ព្រះអង្គ ចូលទៅកាន់ព្រះរាជនិវេសន៍ក្នុងខណៈនេះ " ។

*សម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គ កាលបានទទួលនិមន្តហើយ ក៏ទ្រង់ស្លៀកស្បង់គ្រងចីពរស្ពាយបាត្រទ្រង់យាត្រាទៅតាមមាគ៌ាទាំង ៤ ជា* **លោកុត្តរមាគ៌ា** *តាមលំដាប់គឺ* **សោតៈ** , **សកទាគា** , **អនាគា** , **អរហត្ត** *ដែលជាមាគ៌ាអាចនាំព្រះបាទ* **ចិត្តរាជ** *ចេញផុតពីកណ្ដាប់ដៃនៃ* **មច្ចុរាជ** *ដោយសួស្ដីបាន ។*

*លុះសម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គនិមន្តដោយផ្លូវធំចូលទៅកាន់ព្រះរាជសំណាក់ គង់លើអាសនៈដ៏សមគួរហើយព្រះបាទ* **ចិត្តរាជ** *ក៏នមស្ការបូជាគោរពហើយត្រាស់ពិតថេរដីកាថា ៖*

*" បពិត្រសម្ដេចទាំង ២ ព្រះអង្គ !*

*ញោមមានសេចក្ដីអផ្សុកខ្លាំងណាស់ បានជាឲ្យអារាធនាសម្ដេចជាអម្ចាស់មក ដើម្បីទ្រង់ជួយដោះទុក្ខញោមក្នុងគ្រាឥឡូវនេះ ដ្បិត* **មច្ចុរាជ** *ចេះតែមកបៀតបៀនញោម ដោយគេប្រើមេទ័ពធំទាំង ៤ ព្រមទាំងបរិវារឲ្យមកធ្វើបាបញោម គ្រប់ពេលដែលញោមសាង* **នគរភាយ** *ពុំដែលខានពេលណា ប្រាថ្នាឲ្យញោមនៅក្នុងអំណាចគេ ,*

*បពិត្រសម្ដេចដ៏ចម្រើន ! ធ្វើដូចម្ដេចហ្ន៎ឲ្យញោមបានរួចអំពីកណ្ដាប់ដៃសត្រូវនេះបាន ?" ។*

*សម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គគឺព្រះ* **សមាធិន្ទ្រិយ** *និងព្រះ* **បញ្ញិន្ទ្រិយ** *លុះបានស្ដាប់ព្រះរាជឱង្ការហើយ ក៏ប្រឹក្សាជាមួយនឹងព្រះជីតុនទាំង ៣ រូបគឺ ព្រះ* **អនិច្ចំ** , **ទុក្ខំ** , **អនត្តា** *និងព្រះឥសីទាំង ៣រូបគឺ ព្រះ* **បីតិ** , **ឆន្ទោ** , **វីរិយោ** *។*

*ខ្សែសេចក្ដីថា កាល* **សមាធិ** *និង* **បញ្ញា** *កើតឡើងក្នុងចិត្ត ទើបគិតឃើញ* **ព្រះត្រៃលក្ខណ៍** , *កាល* **ព្រះត្រៃលក្ខណ៍ញ្ញាណ** *កើតមានឡើង តែងមាន* **បីតិ** *( អំណរ ) ជ្រួតជ្រាបទូទៅក្នុងកុសលធម៌ទាំងពួង , មាន* **ឆន្ទៈ** *( ស្រឡាញ់ ) កុសល កាត់* **អកុសល** *បោលបង់មិនត្រេកអរ និងមាន* **វីរិយៈ** *( ព្យាយាម ) ប្រាថ្នាឲ្យផុតចាកសង្សារវដ្ដ ។*

*សម្ដេចព្រះមហាសង្ឃរាជក៏ប្រឹក្សានឹងបុរោហិត ៣ រូបគឺ រាជគ្រូ* **វិតក្កោ** , **វិចារោ** , **អធិមោក្ខោ** *តទៅទៀតថា ៖ " លោកណាយល់យ៉ាងណាខ្លះ ?" ។ រាជគ្រូទាំង ៣ រូបនឹករំពឹងទៅក៏ឃើញទោសរបស់បុគ្គលជាអកុសល ហើយ*

ពិតថេរដីកាថា ៖ " ទូលព្រះបង្គំជាខ្ញុំទាំងឡាយ យល់តាមសម្ដេចទាំងអស់ " ។

កាលបើដូច្នោះ សម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គក៏ប្រឹក្សាសួរទៅឧកញ៉ា ពញា ព្រះហ្លួង ឃុន ហ្មឺន និងមហាតលិកទាំងពួង មានឧកញ៉ាសទ្ធាជាដើមថា ៖ " លោកទាំងអស់នេះ យល់ឃើញដូចម្ដេច ? " ។

វរជនទាំងនោះកាលប្រឹក្សាយល់ត្រូវគ្នា ក៏ពិតថេរដីកាថា ៖ " ទោសទាំងនេះ មកតែពីបាបជនទាំង ១៤ អង្គមានឃុន **មោហោ** ជាដើមជាព្រះញាតិវង្ស , ព្រះបាទ **មោហរាជ** ជាព្រះបិតា , ព្រះនាង **លោភទេវី** ជាព្រះមាតា និងព្រះនាង **អវិជ្ជាទេវី** ជាព្រះអគ្គមហេសី បានស្ម័គ្រយកមេទ័ពទាំង ៤ របស់ **មច្ចុរាជ** មាន **នាយជាតិ** ជាដើមឲ្យមកនៅក្នុង ព្រះ **នគរភាយ** បានជាគេនាំគ្នាធ្វើព្រះនគរនេះឲ្យអន្តរាយអស់ " ។

កាលទីប្រឹក្សាបានពិភាក្សាអស់កាលដ៏យូរ យល់ឃើញព្រមគ្នាហើយ ទើបយកសេចក្ដីក្រាបបង្គំទូលព្រះបាទ **ចិត្តរាជ** ថា ៖

" បពិត្រមហារាជ ដ៏ទ្រង់នូវព្រះរាជសម្ភារៈ !

ហេតុដែលនាំឲ្យខូចព្រះ **នគរភាយ** នេះ ទីប្រឹក្សាបាន ប្រឹក្សាឃើញមូលមតិគ្នាហើយថា មកពីព្រះអង្គទ្រង់ជឿ ពាក្យពួកបាបជនទាំង ១៤ អង្គ មានយុន **មោហោ** ជាដើម ជាព្រះញាតិព្រះអង្គ ជាសត្រូវក្នុងនាំសត្រូវក្រៅមកនៅក្នុង ព្រះនគរ បានជាព្រះនគរកើតអន្តរាយដូច្នេះ មួយទៀតមក ពីព្រះបាទ **មោហរាជ** ជាព្រះបិតា , ព្រះនាង **លោភទេវី** ជាព្រះមាតា និងព្រះនាង **អវិជ្ជាទេវី** ជាព្រះអគ្គមហេសី នៃព្រះអង្គ បានព្រមព្រៀងជាមួយនឹងព្រះញាតិទាំង ១៤ អង្គទទួលយកមេទ័ពព្រះបាទ **មច្ចុរាជ** ទុកក្នុងព្រះនគរ ទើប ពួកបច្ចាមិត្រគេនាំគ្នាធ្វើព្រះ **នគរភាយ** របស់ព្រះអង្គឲ្យ អន្តរាយដូច្នេះ , រឿងនេះបើព្រះអង្គជឿស្ដាប់យើងទាំងឡាយ ជាទីប្រឹក្សា សូមព្រះអង្គកំចាត់បង់ព្រះញាតិវង្សទាំង ១៤ អង្គ ព្រះមាតា - បិតា និងព្រះអគ្គមហេសីចេញ ទើប បច្ចាមិត្រលែងកើតទៀតបាន , ហើយយើងទាំងពួងនឹងនាំ ព្រះអង្គទៅកាន់នគរកែវជាអមតៈមហានគរ ជាទីបរមសុខ ប្រាសចាកទុក្ខផុតពីកណ្ដាប់ដៃនៃ **មច្ចុរាជ** តាមព្រះរាជ បំណងបាន " ។

*កាលព្រះបាទ* **ចិត្តរាជ** *បរមក្សត្រ បានទ្រង់ព្រះសណ្តាប់ហើយ , ដោយទ្រង់មានព្រះរាជបំណងចង់រួចពីកណ្តាប់ដៃនៃ* **មច្ចុរាជ** *ទ្រង់ក៏ធ្វើតាមពាក្យទីប្រឹក្សាទាំងពួងមានសម្តេចព្រះមហាសង្ឃរាជជាដើម ទើបតាំងមហាតលិកម្នាក់ឈ្មោះហ្មឺន* **ឯកគ្គតា** *និងអគ្គសេនាម្នាក់ឈ្មោះឧកញ៉ា* **ចិត្តុជុកតា** *ដែលមានចិត្តស្មោះត្រង់នឹងព្រះអង្គឲ្យជាចៅក្រមជំនុំជម្រះរឿងព្រះញាតិទាំង ១៤ អង្គ នូវព្រះមាតា-បិតា និងព្រះអគ្គមហេសី ព្រមគ្នានៅទីចំពោះព្រះភក្ត្រព្រះអង្គ ។*

*ក្នុងសេចក្តីជំនុំជម្រះនោះ ចៅក្រមសួរថា ៖*

*" នៃព្រះបាទ* **មោហរាជ** *! ព្រះនាង* **លោភទេវី** *! ព្រះនាង* **អវិជ្ជាទេវី** *! លោកទាំងអស់អង្គសុទ្ធតែជាព្រះមាតា-បិតា អគ្គមហេសីនៃព្រះរាជា , ទាំងឃុន ១៤ អង្គក៏សុទ្ធតែជាព្រះញាតិព្រះរាជាទាំងអស់ , ព្រះរាជាទ្រង់ប្រោសប្រាណ តាំងអស់លោកជានាហ្មឺនគ្រប់ ៗ គ្នា , ហេតុដូចម្តេចបានជាអស់លោកមិនគិតរក្សាព្រះអង្គដោយយុត្តិធម៌ បែរជាទៅក្រាបទូលណែនាំការមិនជាប្រយោជន៍ដល់ព្រះអង្គវិញ គឺនាំយកសត្រូវពីក្រៅឲ្យចូលមកនៅក្នុងព្រះនគរ ទាល់តែគេ*

*ធ្វើបាបព្រះអង្គ ធ្វើព្រះនគរព្រះអង្គឲ្យខូចអស់ដូច្នេះ ?, នៃលោកទាំងអស់ ! ចូរលោកប្រាប់យើង ជាប្រញាប់ក្នុងពេលនេះ" ។*

*កាលនោះ ព្រះមាតាក្តី ព្រះបិតាក្តី ព្រះអគ្គមហេសីក្តី ព្រះញាតិទាំង ១៤ អង្គក្តី ពុំអាចឆ្លើយឲ្យការណ៍កែខ្លួនបានឡើយ សឹងតែសារភាពថា ៖ " យើងខ្ញុំទាំងពួងខុសមែន , មានទោសច្រើនមែន , តាមតែទ្រង់មេត្តាប្រោសដល់យើងខ្ញុំចុះ" ។*

*ព្រះ* **ចិត្តរាជា** *កាលបានទ្រង់ព្រះសណ្តាប់ដូច្នោះ ទើបទ្រង់ព្រះរាជបញ្ជាប្រើឧកញ៉ា* **សទ្ធា** *, ជាអគ្គសេនាឲ្យតាំងទីកុណ្ឌ*[១] *ពិធីឡើង ។ គ្រានោះ ហេតុតែវាសនាបារមីព្រះបាទ* **ចិត្តរាជ** *ចាស់ក្លា និងដោយសារឫទ្ធិព្រះឥសីទាំង ៣ រូបគឺ ព្រះ* **បីតិ** *,* **ឆន្ទោ** *,* **វីរិយោ** *លោកសូត្រសែកព្រះវេទមន្តឡើង , ព្រះខាន់ជ័យស្រីទាំង ៣ ក៏កើតឡើងកណ្តាលទីកុណ្ឌពិធីនោះ , ទើបព្រះឥសីទាំងឡាយថ្វាយ*

---

(១) ពិធីដែលគេធ្វើដោយជីករណ្តៅជម្រៅ ១ ចង្អាម ៥ ផ្ទាប់ ដុតភ្លើងបូជាយញ្ញតាមលិទ្ធិព្រាហ្មណ៍ ។

ព្រះពរថា ៖

"កាលនេះ ជាកាលគួរ ដែលព្រះអង្គទ្រង់យាងចូលទៅកាន់ទីកុណ្ឌពិធីហើយ សូមព្រះអង្គទាញយកព្រះខាន់ជ័យស្រីទាំង ៣ អំពីទីកុណ្ឌពិធីនោះចុះ" ។

ព្រះបាទ **ចិត្តរាជ** ព្រះអង្គលូកព្រះហស្តទៅទាញយកព្រះខាន់ជ័យស្រីទាំង ៣ អំពីគំនរភ្លើងនៃកុណ្ឌពិធី សូម្បីនឹងបានក្តៅព្រះហស្តបន្តិចបន្តួចក៏ទេ ។

ឯព្រះខាន់ជ័យស្រីទាំង ៣ នោះឈ្មោះ ៖

១. **គទខ្គប្បហារ** មានដងប្រាក់ អាចញាំញីសត្រូវបានដោយអន្ទើ ៗ ;

២. **ទិក្ខម្ពនប្បហារ** មានដងមាស អាចសង្កត់សង្កិនសត្រូវដូចថ្មសង្កត់ស្មៅមិនឲ្យកម្រើកបាន ;

៣. **សមុច្ឆេទប្បហារ** មានដងវិចិត្រដោយកែវ ៧ប្រការ អាចប្រហារសិរសារាជសត្រូវទាំងឡាយឲ្យដាច់ដូចត្នោតកំបុតក ។

ព្រះបាទ **ចិត្តរាជា** ទ្រង់ចាប់ព្រះខាន់ជ័យស្រីទាំងនោះព្រះរាជទានទៅអគ្គសេនាឈ្មោះឧកញ៉ា **ចិត្តបស្សទ្ធិ** ដែល

មានចិត្តថ្លាដូចកែវឲ្យជារាជតំណាង ដោយទ្រង់ព្រះរាជបញ្ជាថា ៖ " ចូរអ្នកឯងសម្លាប់ព្រះបាទ **មោហរាជ** ជាបិតាយើងដែលនាំឲ្យយើងវង្វេង , ព្រះនាង **លោភទេវី** ជាមាតាយើងដែលនាំឲ្យយើងលោភឥតអៀនខ្មាស , ព្រះនាង **អវិជ្ជាទេវី** ជាអគ្គមហេសីយើងដែលនាំឲ្យយើងងងឹតមុខជ្រប់ទៅតាមវា , ហើយចូរអ្នកឯងសម្លាប់ពួកបាបជនទាំង ១៤ នាក់ ដែលជាព្រះញាតិវង្សយើង ដ្បិតអ្នកអស់នេះវាឲ្យសត្រូវខាងក្រៅចូលមកនៅក្នុងស្រុកយើង ឲ្យសត្រូវធ្វើខូចព្រះនគរយើង, យើងត្រូវតែសម្លាប់វាឲ្យអស់កុំឲ្យសល់ម្នាក់ " ។

ឯឧកញ៉ា **ចិត្តបស្សទ្ធិ** កាលទទួលព្រះរាជបញ្ជាហើយក៏ប្រហារជីវិតជនអំបាលនោះ គ្មានសល់ម្នាក់ ដោយព្រះខាន់ឈ្មោះ **សមុច្ឆេទប្បហារ** ។

**អស់លោក-អ្នកអាន** អ្នកស្តាប់រឿងនេះ សូមកុំយល់ថា ព្រះបាទ **ចិត្តរាជ** មានរូបជាមនុស្សប្រើគេឲ្យសម្លាប់មាតាបិតា . . . មានរូបជាមនុស្សនោះឡើយ , មិនមែនដូច្នោះទេ គឺ **ចិត្ត** សម្លាប់ **ចេតសិក** ដែលទុកដូចជាមាតាបិតា . . .

*ដោយរឿងនេះ លោកលើកយកធម៌ជាធម្មាធិដ្ឋានមកតែង ជាបុគ្គលាធិដ្ឋាន ជាន័យប្រៀបធៀបដើម្បីឲ្យអ្នកមានប្រាជ្ញាតិចយល់បានងាយ ។ ឯព្រះបាទ* **ចិត្តរាជ** *ក៏គឺដួងចិត្តយើងទាំងពួងទាំងឡាយ ,* **នគរកាយ** *ក៏គឺរូបកាយយើងគេទាំងពួងនេះឯង , ទាំងព្រះមាតាបិតាព្រះអគ្គមហេសី និងព្រះញាតិ ១៤ អង្គក៏សុទ្ធតែជាអកុសលចេតសិកទាំងអស់ ។*

*អត្ថបទប្រៀបធៀប ដែលលោកលើកមកសម្ដែងនេះ ត្រូវគ្នានឹងអត្ថបទប្រៀបធៀប ដែលព្រះសម្ពុទ្ធទ្រង់សម្ដែងទុកក្នុងគម្ពីរខុទ្ទកនិកាយធម្មបទ ត្រង់បកិណ្ណកវគ្គថា ៖*

**មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ**
**រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ**

*បុគ្គលសម្លាប់តណ្ហាដូចមាតា , សម្លាប់អស្មិមានៈដូចបិតា , សម្លាប់សស្សតទិដ្ឋិ ឧច្ឆេទទិដ្ឋិទាំងពីរ ដែលដូចខត្តិយរាជពីរព្រះអង្គ និងសម្លាប់អាយតនៈដូចដែន ព្រមទាំងនន្ទិរាគដូចស្មៀន តែងបានជាព្រាហ្មណ៍ ឥតមានទុក្ខទៅព្រះនិព្វាន ។*

កាលឧកញ៉ា **ចិត្តបស្សទ្ធិ** ប្រហារជីវិតជនទាំងនោះអស់ ហើយសម្តេចព្រះមហាសង្ឃរាជ ២ ព្រះអង្គ , ព្រះជីតុន ៣ រូប , ព្រះឥសី ៣ រូប , បុរោហិត ៣ រូប , មហាតលិក ៧ នាក់ និងអគ្គសេនា ១៩ នាក់ ក៏ប្រារព្ធនិងសូមយាង ព្រះបាទ **ចិត្តរាជ** ចេញចាក **នគរកាយ** ។

គ្រានោះសម្តេចព្រះមហាសង្ឃរាជថ្វាយព្រះពរថា ៖

" បពិត្រមហារាជ ដ៏ទ្រង់នូវព្រះបារមី !

សូមព្រះអង្គយាងចុះមក អាត្មាភាពទាំងឡាយនឹងនាំ ព្រះអង្គទៅកាន់ព្រះនគរកែវ ជាស្រុកព្រះអរិយបុគ្គល អាត្មាភាពជាមគ្គទ្ទេសក៏នឹងនាំផ្លូវព្រះអង្គ ទៅក្នុងកាលឥឡូវ នេះ " ។

ឯព្រះបាទ **ចិត្តរាជ** កាលបើសម្តេចព្រះមហាសង្ឃរាជ ទាំង ២ ព្រះអង្គគឺ ព្រះ **សមាធិន្ទ្រិយ** , ព្រះ **បញ្ញិន្ទ្រិយ** បានណែនាំ ( ពោលគឺ **សមាធិ** និង **បញ្ញា** បានកើតក្នុងចិត្ត ក៏ពិចារណាឃើញនូវសភាវធម៌ទាំងពួងតាមពិត ) ហើយ ទើបព្រះអង្គ ទ្រង់តាក់តែងព្រះកាយដោយគ្រឿងទិព្វរ័តន៍- ភូសា សែសយ សង្វារ សូរង កង ព្រះហ៊ូរាក់ស្នាប់ព្រះ

ខ្សែ ប្រកបទៅដោយកញ្ចង់ពិសេស ពោលគឺព្រះពោធិ - បក្ខិយធម៌ ៣៧ ប្រការគឺ **សតិប្បដ្ឋាន ៤** , **សម្មប្បធាន ៤** , **ឥទ្ធិបាទ ៤** , **ឥន្ទ្រិយ ៥** , **ពល ៥** , **ពោជ្ឈង្គ ៧** និង **អដ្ឋង្គិកមគ្គ ៨** ជាគ្រឿងអលង្ការដ៏ល្អ ៗ រុងរឿង ហើយទ្រង់ពាក់នូវព្រះទម្រង់គ្រប់ម្រាមព្រះហស្តទាំង ១០ ពោលគឺ **សិក្ខាបទ ១០** និងទ្រង់នូវព្រះមហាមកុដ ពោល គឺ **សិក្ខាបទ ២២៧** និងទ្រង់នូវក្រោះពេជ្រសម្រាប់ព្រះតេជានុភាពពោលគឺ ព្រហ្មវិហារធម៌ ៤ ប្រការគឺ **មេត្តា** , **ករុណា** , **មុទិតា** និង **ឧបេក្ខា** ហើយទ្រង់នូវព្រះខគ្គាវុធ ពោលគឺ **សមុច្ឆេទប្បហារ** ដែលអាចកាប់កាត់កំចាត់បង់សត្រូវទាំងពួង ពោលគឺ **អកុសល** ទាំងអស់បាន ។ លុះទ្រង់គ្រឿងអលង្ការស្រេចហើយ ទើបទ្រង់យាងឡើងប្រថាប់លើព្រះធម្មរថ ពោលគឺ **ព្រះសទ្ធម្ម ៨៤000 ព្រះធម្មក្ខន្ធ** ហើយក៏ទ្រង់និសីទនាការលើរតនបល្ល័ង្កជាព្រះទីនាំងដ៏ប្រកបដោយកែវ ៩ ប្រការគឺ **ព្រះនព្វលោកុត្តរធម៌ ៩** គឺ **មគ្គ ៤**, **ផល ៤** , **និព្វាន ១** ។ ឯធម្មរថនោះសឹងទឹមដោយសេះសន្ធវជាតិអាជានេយ្យ ៤ គឺ ព្រះចតុប្បារិសុទ្ធិសីល ទាំង ៤ គឺ **បាតិមោក្ខសំវរសីល**, **ឥន្ទ្រិយសំវរសីល**, **អាជីវបារិសុទ្ធិ-**

**សីល** និង **បច្ចយសន្និស្សិតសីល** ។ ធម្មអាជានេយ្យទាំង ៤ នេះ ក៏ទាញនូវព្រះធម្មរថឲ្យអណ្តែតត្រសែតឡើងលើនភាល័យ , ហើយព្រះបាទ **ចិត្តរាជ** បរមក្សត្រព្រះអង្គប្រកបដោយឥទ្ធិឫទ្ធិ ៤ ប្រការ ពោលគឺ **ឆន្ទិទ្ធិបាទ** ( ឫទ្ធិសម្រេចដោយសេចក្តីប្រាថ្នា ) , **វិរិយិទ្ធិបាទ** ( ឫទ្ធិសម្រេចដោយសេចក្តីព្យាយាម ) , **ចិត្តិទ្ធិបាទ** ( ឫទ្ធិសម្រេចដោយចិត្ត ) , វីមំសិទ្ធិបាទ (ឫទ្ធិសម្រេចដោយបញ្ញា ) ហើយទ្រង់បានត្រាស់ដឹងនូវព្រះញាណទាំង ៤ ប្រការគឺ **បុព្វេនិវាស - ញ្ញាណ** , **ទេសានុជ្ញាណ** , **អនាវរណញ្ញាណ** និង **សព្វញ្ញុតញ្ញាណ** ។

វរជនទាំងឡាយ មានសម្តេចព្រះមហាសង្ឃរាជជាមគ្គុទេសក៏ បាននាំព្រះបាទ **ចិត្តរាជ** ទៅតាមមាគ៌ាទាំង ៤ គឺ **សោតៈ** , **សកទាគា** , **អនាគា** , **អរហត្ត** ជាផ្លូវលោកុត្តរៈរបស់ព្រះអរិយបុគ្គលទាំងពួងពីបុរាណ ។ ព្រះបាទ **ចិត្តរាជ** ក៏អណ្តែតត្រសែតលឿនលើវេហាស៍ កណ្តាលហ្វូងយោធាវេហ៍ពល បានទៅដល់ព្រះនគរកែវជាស្រុកក្សេម - ក្សាន្តប្រាសចាកទុក្ខ ពោលគឺអមតមហានគរនិព្វានជាឋានបរមសុខប្រសើរផុតពីកណ្តាប់ដៃនៃ **មច្ចុរាជ** គឺសេចក្តីស្លាប់

**មច្ចុរាជ** មិនអាចតាមបំផ្លាញព្រះអង្គដូចពីមុនបាន ដោយហេតុព្រះអង្គយាងចូលស៊ប់ទៅក្នុង **ព្រះនគរកែវ** គឺព្រះនិព្វានដ៏មានកំពែងកែវ ៧ [១] ជាន់ជិតជុំមាំមួនក្រៃពេក ជាព្រះនគរដ៏ប្រាសចាកទុក្ខទាំង ៤ កងគឺ **ជាតិទុក្ខ** , **ជរាទុក្ខ** , **ព្យាធិទុក្ខ** , **មរណទុក្ខ** ឥតជិតដល់យល់ឃើញឡើយ ។

ព្រះបាទ **ចិត្តរាជ** បរមក្សត្រ ព្រះអង្គបានគង់នៅជាបរមសុខក្នុងឋានព្រះនិព្វាន ដូចបានពណ៌នាមក ។

**ធម្មកថានេះ** ពណ៌នាតាមលំអានបរមត្ថធម៌ដែលព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់សំដែងអំពី **កាយ** និង **ចិត្ត** ជាផ្លូវធម៌ធៀបផ្លូវលោក ដើម្បីពន្យល់សាធុជនដែលបានអានបានស្តាប់ ឲ្យយល់ច្បាស់នូវទោសនៃ **ជាតិ ជរា ព្យាធិ មរណៈ** ដែលនាំសត្វឲ្យហែលវិលវង់ប្វេងប្វុងនៅក្នុងសមុទ្រនៃវដ្តសង្សារ ។

(១) សត្តពោជ្ឈង្គទាំង ៧ គឺ **សតិសម្ពោជ្ឈង្គ** , **ធម្មវិចយសម្ពោជ្ឈង្គ** , **វីរិយសម្ពោជ្ឈង្គ** , **បីតិសម្ពោជ្ឈង្គ** , **បស្សទ្ធិសម្ពោជ្ឈង្គ** , **សមាធិសម្ពោជ្ឈង្គ** , **ឧបេក្ខាសម្ពោជ្ឈង្គ** ទុកជាកំពែងការពារ ។

សាធុជនដែលបានអានបានស្តាប់នូវស័ព្ទព្រះធម៌នេះ គប្បីក្តួចកត់កំណត់ចាំឲ្យជាក់ច្បាស់គ្រប់ន័យ , ន័យត្រង់ណាដែលធម្មកថានេះពោលសង្ខេប គឺគ្រាន់តែរាប់ឈ្មោះពុំបានប្រែ ពុំបានអធិប្បាយ ឬអធិប្បាយដោយខ្លី ៗ បើស្តាប់សេចក្តីពុំបាន គប្បីសាកសួរប្រឹក្សាដល់បណ្ឌិតបរមត្ថសាស្ត្រ ដែលឆ្លៀវឆ្លាសក្នុងបរមត្ថធម៌ឲ្យលោកពន្យល់តទៅ ។

សូមសេចក្តីសុខ សេចក្តីចម្រើន កើតមានដល់លោកអ្នកអាន អ្នកស្តាប់ទាំងឡាយ សព្វ ៗ កាល !

**ចាប ពិន**

*ចម្លងចប់នៅក្រុងម៉ុងរេអាល, ថ្ងៃទី២៨ ខែកុម្ភៈ ២០១១

**ម៉ាត និរក្ស**

# សមាសភាពចូលរួម

១. ខ្សាសក មុិញ សាវ៉ាន

២. លោក វ៉ាត សុគន្ធ

៣. លោក វ៉ាត តារា ( ទីទី )

៤. លោក វ៉ាត មុ៉ូលីវណ្ណា

៥. កញ្ញា វ៉ាត វារីយ៉ា



# នាមពុទ្ធបរិស័ទ
## មានសទ្ធាជ្រះថ្លាបានបរិច្ចាគបច្ច័យ
## ដើម្បីបោះពុម្ពសៀវភៅជាធម្មទាន ៖

. *ព្រះភិក្ខុ* **ធឹង ធីម** ( **ចន្ទត្ថេរ** ) *ចៅអធិការវត្ត* **ធម្មិការាម**
. *ព្រះភិក្ខុ* **ហ៊ុន ឃួយ** *វត្ត* **ធម្មិការាម**
. *ព្រះភិក្ខុ* **ស៊ុំ ម៉ុនធៀម** ( **សុវណ្ណត្ថេរោ** ) *វត្ត* **ពុទ្ធសុទ្ធារាម**
. *ព្រះភិក្ខុ* **ពិន ហោ** ( **ធម្មសារោ** )
. *ព្រះភិក្ខុ* **ប៉ាវ សែន** *វត្ត* **ពុទ្ធស្ថានខ្មែរម៉ុងរេអាល Anjou**
. *លោក* **កែវ សម៉នឈាង**
. *ពុទ្ធបរិស័ទ* **វង្ស តក្របូរីយ៍**
. *លោកយាយ* **ចាន ផាន់**
. *លោកយាយ* **ដាន យុតហ្វ**
. *លោកយាយ* **ត្វ ស៊ីវលន់**
. *លោកតា* **ម៉ុញ មឿន**
. *លោកយាយ* **ស៊ុត គិមហាន**
. *លោកយាយ* **នូ លឹម**
. *ឧបាសិកា* **ឡុត យឿម**
. *ឧបាសក* **ម៉ែន សារឿន** *និងឧបាសិកា* **ឡាំ ឈួម**
. *ឧបាសក* **ម៉ិញ សាវ៉ាន** *និងឧបាសិកា* **សិម ចាន់ធូរ៉ា**
. *ឧបាសិកា* **ម៉ៅ វេង**
. *ឧបាសក* **ផាន សុផុន** *និងឧបាសិកា* **ឈឿង យ៉ាវ**

. *លោក* **ផាន សុផៃរតន:**
. *លោកស្រី* **ផាន ម៉ារីសុរិយា**
. *ឧបាសក* **អ៊ូ សុផុន** *និងឧបាសិកា* **អ៊ូ សុខន**
. *ឧបាសក* **ហ៊ុន ហេង** *និងឧបាសិកា* **ឆាង រ៉ម**
. *ឧបាសិកា* **អោយ យាន** *ព្រមទាំងកូនចៅ*
. *ឧបាសិកា* **អ៊ុន យូឡេង**
. *អ្នកស្រី* **អ៊ុន យូសេង**
. *ឧបាសក* **ខាំផាន់ ម៉ាលីថៃ** *និងឧបាសិកា* **ម៉ា ថងអន**
. *ឧបាសិកា* **ទេព ឆុង**
. *ឧបាសិកា* **អ៊ាប គិមជា**
. *ឧបាសិកា* **ស៊ុយ ជាមួយ**
. *ឧបាសិកា* **អ៊ឹង ឆាយហ៊ុន**
. *ឧបាសិកា* **តែ ងឹងអ៊ី**
. *ឧបាសក* **អ៊ឹម កុសល** *និងឧបាសិកា* **តែ ងឹងលាភ**
. *ឧបាសក* **ខាយ ប៊ុនគីម** *និងឧបាសិកា* **ស សុខឆេង**
. *ឧបាសក* **ម៉ម លន់** *និងឧបាសិកា* **ផ្លែង ង៉ឿន**
. *ឧបាសក* **អ៊ឹម សាម៉ៃ** *និងឧបាសិកា* **ភួង ង៉ឿន**
. *ឧបាសក* **ផល់ ផាន់** *និងឧបាសិកា* **យូ ហ៊ី**
. *ឧបាសិកា* **ជា ឆាង**
. *ឧបាសិកា* **ជា ស្រីយុទ្ធថូ**
. *អ្នកស្រី* **មៀច ស៊ីថុល**
. *ឧបាសក* **ហ៊ុន លឹមហ៊ាង**

. *លោក* **សិម សារឿន** *និងអ្នកស្រី* **ចាន់ ដារី**

. *លោក* **ពេជ្រ សារឿម** *និងអ្នកស្រី* **សិម ចាន់ដារ៉ា**

. *លោក* **សិម សទ្ធា** *និងអ្នកស្រី* **ពេជ្រ រីលីន**

. *យុវជន* **សិម រតនា**

. *លោក* **តាយ យ៉ន** *និងអ្នកស្រី* **សិម ចាន់នី**

. *លោក* **យឹត សូណាត** *និងអ្នកស្រី* **ហ៊ុន ម៉ារ៉ានី**

. *លោក* **សិម វី** *និងអ្នកស្រី* **សិម ចិន្តា**

. *លោក* **ខៃ ឃុនហៃ** *និងអ្នកស្រី* **សិម ចាន់ធូរ៉ាណា**

. *យុវជន* **សិម រីឆា**

. *លោក* **សិម សុមេរ៉ា**

. *អ្នកស្រី* **ជា ពិសី**

. *កុមារ* **សិម ប៊ីលី**

. *កុមារ* **សិម លីណូ**

. *អ្នកស្រី* **សិម ទេវី**

. *អ្នកស្រី* **ស៊ុំ យ៉ាខ**

. *អ្នកស្រី* **ណាវ វ៉ាន់នី**

. *លោក* **ជួប បុរីវុទ្ធ** *និងអ្នកស្រី* **សួស ចាន់សីម៉ា**

. *លោក* **មួច សុធា** *និងអ្នកស្រី* **ខៃ៉ត ផាន់នី**

. *អ្នកស្រី* **តាយ តិរម្យ**

. *យុវនារី* **តាយ តាវី**

. *លោក* **លី វីមុត** *និងអ្នកស្រី* **សិម ចាន់ណារី**

. *លោក* **សួស ប៉ុណ្ណាវុធ** *និងអ្នកស្រី* **សិម វិច្ឆិកា**

. *កុមារ* **សិម ឡេអូ**

. *កុមារ* **សិម ប៊ីលីយ៉ាម**

. *លោក* **ចៅ សុខ** *និងអ្នកស្រី* **ឈឹម សុនី**

. *លោក* **ទូច សាន** *និងអ្នកស្រី* **ស៊ុយ សាម៉ុន**

. *លោក* **នុន ស្បៃ** *និងអ្នកស្រី* **នុន ណាន់ថា**

. *លោក* **លី សាម៉ន** *និងអ្នកស្រី* **ញឹក ស្រីភាព**

. *លោក* **អ៊ួង ហ៊ាង** *និងអ្នកស្រី* **ប៉ែន យិម**

. *លោក* **លី គាង** *និងអ្នកស្រី* **អ៊ុក គិមហ៊ាង**

. *លោក* **នូ ស៊ីយឿន** *និងអ្នកស្រី* **លី សុភី**

. *លោក* **ភិច នូភាន** *និងអ្នកស្រី* **សេម ស៊ីភាឆូក**

. *លោក* **អៀម រឿន** *និងអ្នកស្រី* **ភី រិម**

. *អ្នកស្រី* **ផាត់ សាវឡា**

. *លោក* **ផាត់ សុភឡិត** *និងអ្នកស្រី* **ឆៃ សុភិន**

. *លោក* **សក្តិ ផល្លា** *និងអ្នកស្រី* **ចាន់ សុម៉ាលី**

. *យុវជន* **ផល្លា ពិសិដ្ឋ**

. *លោក* **យន់ សាវុធ** *និងអ្នកស្រី* **ណាម នី**

. *អ្នកស្រី* **ហ៊ុន ហ៊ាង**

. *លោក* **ពិន ឃឹមខុន** *និងអ្នកស្រី* **ប៉្រេង ហួវ**

. *លោក* **ហេង ចាន់ថា** *និងអ្នកស្រី* **អ៊ុំ ភឿន**

. *លោក* **ឃុំ ម៉ែន**

. *អ្នកស្រី* **ភ្លឹម ហ៊ុត**

. *លោក* **ឃុំ មាន** *និងអ្នកស្រី* **សួន ស៊ីសុវណ្ណា**

| | | | | | |
|---|---|---|---|---|---|
| . *លោក* | **ខួន** | **សុវណ្ណា** *និងអ្នកស្រី* | | **ឃុំ** | **ហែម** |
| . *លោក* | **ហួត** | **គិមតាវ** *និងអ្នកស្រី* | | **ភិវ** | **ស៊ីនួន** |
| . *លោក* | **ឱប** | **ច័ន្ថា** | *និងអ្នកស្រី* | **លៀម** | **សុភាព** |
| . *លោក* | **សេក** | **សារុន** | | | |
| . *លោក* | **នូ** | **សារឿន** | | | |
| . *លោក* | **ជួន** | **កែវ** | *និងអ្នកស្រី* | **ហង់** | **សំអឿន** |
| . *លោក* | **អែម** | **ណាវី** | *និងអ្នកស្រី* | **អាត** | **សំណាង** |
| . *លោក* | **អ៊ុំ** | **ហំ** | *និងអ្នកស្រី* | **ទិម** | **ណាវី** |
| . *លោក* | **ជី** | **ស៊ុនហេង** *និងអ្នកស្រី* | | **អាង** | **ពៅ** |
| . *លោក* | **ជិន** | **ចាន់ដារ៉ា** *និងអ្នកស្រី* | | **សេង** | **វ៉ាន់នី** |
| . *លោក* | **ខួន** | **សារុន** | *និងអ្នកស្រី* | **ហួ** | **ចាន់ណា** |
| . *លោក* | **ទិម** | **សៀប** | *និងអ្នកស្រី* | **អ៊ីម** | **វ៉ាន** |
| . *អ្នកស្រី* | **ខួច** | **ជីវសេង** | | | |
| . *អ្នកស្រី* | **លិម** | **មួយគិច** | | | |
| . *អ្នកស្រី* | **ហាន** | **គិម** | | | |
| . *លោក* | **គិម** | **ដេត** | | | |
| . *អ្នកស្រី* | **គិម** | **ហាន** | | | |
| . *យុវជន* | **ប្រាក់** | **ចាន់តារ៉ា** | | | |
| . *យុវនារី* | **ប្រាក់** | **ចាន់ដារី** | | | |
| . *អ្នកស្រី* | **វ៉ាន់** | **ហាន** | | | |
| . *អ្នកស្រី* | **គិន** | **សា** | | | |
| . *លោក* | **គិន** | **ណាង** | | | |

. *លោក* **ភង កុសល**

. *អ្នកស្រី* **មួយ**

. *លោក* **ម៉ុញ្ញ វ៉ាន់ថា** *និងអ្នកស្រី* **ជីវ សុផាន់នី**

. *លោក* **ទឹន រតនៈ** *និងអ្នកស្រី* **ភេង សោភា**

. *លោក* **វ៉ាត តិរក្ស** *និងអ្នកស្រី* **មៀច វណ្ណា**

. *លោក* **វ៉ាត តារា** ( **ធីធី** )

. *លោក* **វ៉ាត ម៉ូលីវណ្ណា**

. *កញ្ញា* **វ៉ាត វារីយ៉ា**

. *លោក* **វ៉ាត សុគន្ធ**

. *លោក* **ថាំង សុធា**

. *អ្នកស្រី* **សូហ្វី**

. *លោក* **ឱក សូវៀត** *និងអ្នកស្រី* **ទេព វណ្ណា**

. *លោក* **មាស ឧត្តរោ** *និងអ្នកស្រី* **ជិន ចន្ថា**

. *លោក* **អ៊ុក ចាប** *និងអ្នកស្រី* **ហ៊ុន ផលរ័ត្ន**

. *លោក* **ថាវរី**

. *លោក* **តូ ម៉េងហុង** *និងអ្នកស្រី* **ឱក គិមហ៊ាង**

. *យុវជន* **តូ គិតឡាយ**

. *យុវជន* **តូ គិតលី**

. *យុវជន* **តូ គិតអាឡិចសង់ឌ្រឹះ**

. *កញ្ញា* **តូ សុនដារីស**

. *លោក* **ចៅ ច៉ាន់**

. *អ្នកស្រី* **គុយ ឃួង**

. *យុវជន* **វាលសុន សខាយ**
. *កញ្ញា* **ផល់ សុខឌី**
. *លោក* **ជីវ សុខាល័យ** *និងអ្នកស្រី* **លៀម ស៊ីណាត**
. *លោក* **ថង បៃ** *និងអ្នកស្រី* **សាល្មួន ស៊ីសុវណ្ណា**
. *លោក* **យូ ផាឡែន** *និងអ្នកស្រី* **សិម លក្ខិណា**
. *អ្នកស្រី* **យឹម ច័ន្ទឌី**
. *លោក* **ស្ងួន ច័ន្ទវេហា**
. *លោក* **ប៊ុនច័ន្ទ ប្រហ្មដេរីក**
. *លោក* **ប៊ុនច័ន្ទ ស្ទីវិន**
. *លោក* **គិប វិបុល** *និងអ្នកស្រី* **ស៊ុំ សោភ័ណ្ឌា**
. *លោក* **ខ្វាន់ ប៊ុណ្ណា**
. *លោក* **ឡាំ ស្ទីស** *និងអ្នកស្រី* **គិប សិរីសោភា**
. *លោក* **ទេង ណាំ** *និងអ្នកស្រី* **សក់ សាន់នី**
. *លោក* **ផាន ប៊ិត** *និងអ្នកស្រី* **លឹម ហួវ**
. *លោក* **អ៊ុង ងួនវិសាល** *និងលោក* **អ៊ុង ងួនវិចត័រ**
. *លោក* **ឈឿង ឆាត** *និងអ្នកស្រី* **ផាន ដានី**
. *ឧបាសក* **ម៉ៅ សាន់** *និងឧបាសិកា* **ម៉ៀន ឈុំ**
. *អ្នកស្រី* **ឡាង ទេត**
. *ឧបាសិកា* **គង់ ញ៉ូ** *និងអ្នកស្រី* **ជុំ វ៉ានី**
. *ឧបាសក* **គង់ យុទ្ធ** *និងឧបាសិកា* **តោ ប៉ៀន**
. *លោក* **ថឹម រឹមរ៉ុម** *និងអ្នកស្រី* **ឱក ចន្ទក្រិស្នា**
. *លោក* **លិម ប៉ាង** *និងអ្នកស្រី* **លឿង ទូច**

. *លោក* **ប្រាង សន** *និងអ្នកស្រី* **ទួន សុធាណា**

. *ឧបាសិកា* **ត្រឹង វ៉ែន**

. *ឧបាសក* **ឡាវ លាងថេង**

. *ឧបាសិកា* **ចំណាន**

. *ឧបាសិកា* Son Josie

. *លោក* **តាន់ ប៊ុនតិក** *និងអ្នកស្រី* **តាន់ ថានី**

. *ឧបាសក* **ហ៊ុម ឆាន់** *និងឧបាសិកា* **សាមិត សូភ័ណា**

. *ឧបាសក* **អៀត ហ៊ុត**

. *លោក* **ប៉េង គ្រី** *និងអ្នកស្រី* **ប៊ុនលី**

. *ឧបាសិកា* **អ៊ឹង គង់មន្ថា**

. *ឧបាសិកា* **ណោត សារុន**

. *លោក* **អ៊ូច ទ៊ឹក** *និងអ្នកស្រី*

. *លោក* **លឹម ឆេងហ៊ិន** *និងអ្នកស្រី* **ឈឿង សុខចេង**

. *កញ្ញា* **ហ៊ី ស៊ីលវី**

. *កុមារ* **ហ៊ី ហាក់សៀន**

. *លោក* **ស៊ិទ្ធ សា៉រ៉ាក់** *និងអ្នកស្រី* **ឱត រ៉ុង**

. *លោក* **គី គីឡាំ** *និងអ្នកស្រី* **តាន វ៉ាន់នី**

. *ឧបាសិកា* **នី ហៀងឡាញ់**

. *លោក* **ភក់ គន** *និងអ្នកស្រី* **ប្រាង ប្រង**

*សូមពុទ្ធបរិស័ទដែលបានចូលរួមបោះពុម្ពសៀវភៅនេះ

បានសម្រេចនូវសម្មាទិដ្ឋិគ្រប់ៗជាតិ

និងបានឧបនិស្ស័យរួចផុតចាកទុក្ខទាំងពួង

កុំបីឃ្លៀងឃ្លាតឡើយ !

**សូមអនុមោទនា** !!!

# ជូនពរព្រះពុទ្ធសាសនា



សូមឲ្យព្រះពុទ្ធសាសនារុងរឿងចំរើន

សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញពិភពលោក

សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព

ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ**

ពុំមានសេចក្តីសុខដទៃក្រៅពីសេចក្តីស្ងប់ឡើយ ។

" នគរកាយ " ដែលគ្រប់គ្រងដោយព្រះបាទ **ចិត្តរាជ** ដែលធ្លាប់តែមានសេចក្ដីសុខក្សេមក្សាន្ត ត្រូវបានព្រះបាទ **មច្ចុរាជ** ជានគរជិតខាង បញ្ជូនចារបុរសទាំង ៤ នាក់ ( **នាយជាតិ** , **នាយជរា** , **នាយព្យាធិ** និង **នាយមរណៈ** ) ម្ដងមួយ ៗ មកធ្វើវិច្ឆេទកម្ម , រុករានទន្ទ្រានឈ្លានពានក្នុងព្រះ **នគរកាយ** ព្រះអង្គម្ដងហើយម្ដងទៀតឥតឈប់ឥតឈរ . . .

**តើ**ព្រះបាទ **ចិត្តរាជ** នឹងត្រូវព្រឈមមុខ , រិះរកវិធីដោះស្រាយយ៉ាងណាហ្ន៎ . . . ដើម្បីឲ្យបានរួចអំពីកណ្ដាប់ដៃនៃសត្រូវដ៏កំណាចនេះបាន ? . .

**គឺ**ជាស្នាដៃរបស់លោក ឧត្តមប្រឹជាំ **ចាប ពិន** **និពន្ធបណ្ឌិត** បានរៀបរៀងតាមលំអានសាស្ត្រាស្លឹករឹត ដើម្បីជួយអប់រំបន្ទំនិស្ស័យដល់អ្នកសិក្សា អាន, មើល, ស្ដាប់ឆាប់ចូលចិត្តសេចក្ដីបាន ។

*ចម្លងតាមច្បាប់ដើមដោយខ្ញុំព្រះករុណា ខ្ញុំបាទ **ទ៉ាត តិរត្ន**

**សម្រាប់ជាធម្មទាន**